# ១១

# លោហៈអាល់កាឡាំង

## (The Alkali Metals)

ជាធម្មតាគេគិតថា លោហៈមានដង់ស៊ីតេធំ និងគ្មានប្រតិកម្មភាពទេ។ ប៉ុន្តែចំពោះលោហៈអាល់កាឡាំងមានលក្ខណៈខុសគេ ព្រោះវាមានដង់ស៊ីតេតូចហើយមានប្រតិកម្មភាពខ្លាំងទៀត។

សមាសធាតុនៃលោហៈអាល់កាឡាំងត្រូវបានគេដឹងតាំងពីសម័យបុរាណមកម្លេះ។ ប៉ុន្តែ កាចុងលោហៈអាល់កាឡាំងពិបាករងរេដុកម្មណាស់រហូតដល់មានថាមពលអគ្គិសនី ដែលធ្វើឱ្យលោហៈនេះអាចត្រូវបានញែកចេញ។ អ្នកវិទ្យាសាស្ត្រចក្រភពអង់គ្លេសម្នាក់ឈ្មោះ Humphry Davy, បានធ្វើអគ្គិសនីវិភាគប៉ូតាស្យូមអ៊ីដ្រុកស៊ីតរលាយ នៅឆ្នាំ១៨០៧ ដោយញែកបានលោហៈអាល់កាឡាំងមុនគេបង្អស់។

ជាតិនិយមត្រូវបានត្បាញបញ្ចូលជាមួយគីមី។ នៅពេល Napoleon បានលឺពីការរកឃើញរបស់លោក Davy គាត់បានខឹងសំបាយ៉ាងខ្លាំង ព្រោះអ្នកគីមីវិទូជនជាតិបារាំងមិនមែនជាអ្នករកឃើញមុនគេ។ ប៉ុន្តែនៅពេលនោះដែរ អ្នកគីមីវិទូជនជាតិបារាំងមួយរូបឈ្មោះ Marguerite Perey ជាអ្នករកឃើញលោហៈអាល់កាឡាំងមួយដែលជាអ៊ីសូតូបនៃធាតុវិទ្យុសកម្មក្នុងឆ្នាំ1939។ នាងក៏បានដាក់ឈ្មោះវាថាជាប្រង់ស្យូម (Fr) ស្រដៀងនិងឈ្មោះប្រទេសកំនើតរបស់នាង (France)។ នៅពេលនោះធ្វើឱ្យ Napoleon សប្បាយយ៉ាងខ្លាំង។

### ១១.១ លក្ខណៈរូប

គ្រប់លោហៈអាល់កាឡាំងទាំងអស់មានផ្លេកលោហៈ ហើយមានពណ៌ដូចប្រាក់។ ដូចជាលោហៈដទៃទៀតដែរ លោហៈអាល់កាឡាំងមានកម្រិតចម្លងអគ្គិសនី និងកំដៅខ្ពស់។ ប៉ុន្តែលក្ខណៈខ្លះរបស់ពួកវាមិនធម្មតាទេ។ ឧទាហរណ៍ៈ ដូចជាលោហៈអាល់កាឡាំងជាលោហៈទន់ហើយពួកវាកាន់តែទន់ពីលើចុះក្រោមក្នុងក្រុម។ ដូចនេះ លីចូមអាចកាត់នឹងកាំបិតបាន ប៉ុន្តែប៉ូតាស្យូមអាចច្របាច់ដែលទន់ដូចជាប៊ឺរ។

លោហៈជាច្រើនមានចំណុចរលាយខ្ពស់ ប៉ុន្តែលោហៈអាល់កាឡាំងមានចំណុចរលាយទាប ហើយកាន់តែទាបពីលើចុះក្រោមក្នុងក្រុមទីមួយតែកាន់តែធ្ងន់ ដែលសេស្យូមរលាយនៅសីតុណ្ហភាពលើ សីតុណ្ហភាពបន្ទប់បន្តិចតែប៉ុណ្ណោះ។ ជាក់ស្តែងការបញ្ចូលគ្នានៃកំរិតចម្លងកំដៅខ្ពស់ និងចំណុចរលាយទាបធ្វើឱ្យសូដ្យូមមានប្រយោជន៍ជាឧបករណ៍ចម្លងកម្តៅក្នុងរេអាក់ទ័រនុយក្លេអ៊ែខ្លះ។ ភាពទន់ និងចំណុចរលាយទាបនៃលោហៈអាល់កាឡាំង អាចត្រូវបានកំណត់ថាមានសម្ព័ន្ធលោហៈខ្សោយណាស់ក្នុងធាតុទាំងនេះ។ ឧទាហរណ៍ៈ លោហៈតំណាងមួយ អង់តាល់ពីនៃអាតូមកម្មគឺក្នុងចន្លោះ 400 ទៅ 600 $kJ.mol^{-1}$

ប៉ុន្តែក្នុងតារាង 11.1 ខាងក្រោម លោហៈអាល់កាឡាំងទាំងនោះ ទាបខ្លាំងណាស់។ ជាក់ស្តែងវាមានទំនាក់ទំនងគ្នារវាងភាពទន់និងចំណុចរលាយ និងអង់តាល់ពីនៃអាតូមកម្មទាប។

**តារាង 11.1 ចំណុចរលាយ និងអង់តាល់ពីនៃអាតូមកម្មរបស់លោហៈអាល់កាឡាំង**

| ធាតុ | ចំណុចរលាយ ($^oC$) | $\Delta H$ (kJ.mol$^{-1}$) |
|---|---|---|
| Li | 180 | 162 |
| Na | 98 | 108 |
| K | 64 | 90 |
| Rb | 39 | 82 |
| Cs | 29 | 78 |

លក្ខណៈមិនប្រាកដនោះជាដង់ស៊ីតេនៃលោហៈអាល់កាឡាំង។ លោហៈភាគច្រើនមានដង់ស៊ីតេចន្លោះពី 5 ទៅ 15 g.cm$^{-3}$ ប៉ុន្តែលោហៈអាល់កាឡាំងទាំងនេះមានដង់ស៊ីតេទាបជាងនេះ។

**តារាង 11.2 ដង់ស៊ីតេនៃលោហៈអាល់កាឡាំង**

| ធាតុ | ដង់ស៊ីតេ (g.cm$^{-3}$) |
|---|---|
| Li | 0.53 |
| Na | 0.97 |
| K | 0.86 |
| Rb | 1.53 |
| Cs | 1.87 |

ជាក់ស្តែងលីចូមមានដង់ស៊ីតេ $1\frac{1}{2}$ នៃទឹក។ ជាមួយដង់ស៊ីតេទាបនេះ លីចូមនឹងមិនអាចលិចទេ លើកលែងតែលក្ខណៈមួយទៀតនៃលោហៈអាល់កាឡាំង គឺប្រតិកម្មភាពគីមីខ្ពស់ៗ។ លោហៈទាំងនេះជាធម្មតាត្រូវគេរក្សាទុកក្នុងប្រេង ព្រោះពេលពួកវានៅក្នុងខ្យល់ស្រទាប់ដ៏ក្រាស់នៃផលិតផលអុកស៊ីតកម្មនឹងមានផ្ទៃរលោងនៃលោហៈនីមួយៗ។ ឧទាហរណ៍: លីចូមរងអុកស៊ីតកម្ម ជាលីចូមអុកស៊ីតដែលប្រតិកម្មបន្តជាមួយ $CO_2$ នឹងបានលីចូមកាបូណាត។

$$4Li(s) + O_2(g) \rightarrow 2Li_2O(s)$$
$$Li_2O(s) + CO_2(g) \rightarrow Li_2CO_3(s)$$

លោហៈអាល់កាឡាំងប្រតិកម្មភាគច្រើនជាមួយអលោហៈ។ ឧទាហរណ៍: គ្រប់លោហៈអាល់កាឡាំងរលាយ ឆេះក្នុងឧស្ម័នក្លរ ផ្តល់នូវផ្សែងពណ៌សនៃលោហៈក្លរួ។ ប្រតិកម្មនៃសូដ្យូមជាមួយឌីក្លរតាងឱ្យប្រតិកម្មគីមីដ៏អស្ចារ្យដែលជាប្រតិកម្មដ៏ខ្លាំងក្លា លោហៈគ្រោះថ្នាក់ប្រតិកម្មជាមួយឧស្ម័នពុលគេទទួលបានសមាសធាតុមួយដែលសំខាន់បំផុតសម្រាប់ជីវិត។

$$2Na(l) + Cl_2(g) \rightarrow 2NaCl(s)$$

ប្រតិកម្មនៃលោហៈអាល់កាឡាំងជាមួយទឹកកើតឡើងដោយឯកឯង ដែលប្រតិកម្មភាពកើនឡើងពីលើចុះក្រោមក្នុងក្រុម ។ ខាងក្រោមជាសមីការរវាង ប៉ូតាស្យូម និង ទឹក:

$$2K(s) + 2H_2O(l) \rightarrow 2KOH(aq) + H_2(g)$$

ព្រោះតែវាមានប្រតិកម្មភាពខ្លាំងក្លាជាងលោហៈដទៃទៀតដូចនេះ លោហៈអាល់កាឡាំងជួនកាលគេថាវាជា *ស៊ុបពែលោហៈ*។

## ១១.២ លក្ខណៈពិសេសនៃសមាសធាតុលោហៈអាល់កាឡាំង

គ្រប់ធាតុទាំងអស់ក្នុងក្រុមទីមួយជាលោហៈ ដែលមានលក្ខណៈពិសេសរបស់វា លើកលែងអ៊ីដ្រូសែន ។ អ៊ីយ៉ុងលោហៈអាល់កាឡាំងមានចំនួនអុកស៊ីតកម្ម $+1$ ហើយសមាសធាតុវាភាគច្រើនមានស្ថេរភាព ជាអង្គធាតុរឹងអ៊ីយ៉ូនិច ។ សមាសធាតុរបស់វាគ្មានពណ៌ទេ បើគ្មានអាញ៉ុងមានពណ៌ដូចជាអ៊ីយ៉ុងក្រូម៉ាត ឬអ៊ីយ៉ុងពែម៉ង់កាណាតក្នុងនោះ ។ ទោះបីជាចំពោះធាតុដែលមានអេឡិចត្រូវិជ្ជមានខ្ពស់ក៏ដោយ សម្ព័ន្ធនៅក្នុងសមាសធាតុវាជាមួយអលោហៈមានសមាសភាគកូវ៉ាឡង់តូច ។

### ក. ស្ថេរភាពនៃអាញ៉ុងខ្លាំង

ព្រោះកាចុងនៃលោហៈអាល់កាឡាំង (លើកលែងលីចូម) មានទំហំធំបំផុតហើយដង់ស៊ីតេដែលមានបន្ទុកទាបបំផុត ពួកវាអាចមានស្ថេរភាពខ្លាំងជាអាញ៉ុងមានបន្ទុកខ្សោយ ។ ឧទាហរណ៍: ពីអ៊ីយ៉ុងសូដ្យូមដល់អ៊ីយ៉ុងសេស្យូមគឺជាកាចុងដែលអាចបង្កើតអំបិលអង្គធាតុរឹងអ៊ីដ្រូសែនកាបូណាត ។

### ខ. អ៊ីដ្រាតកម្មអ៊ីយ៉ុង

គ្រប់អ៊ីយ៉ុងរងអ៊ីដ្រាតកម្មនៅពេលវារលាយក្នុងទឹក ។ ប៉ុន្តែ វាមិនពិតទាំងអស់ទេក្នុងផាសអង្គធាតុរឹង ។ អ៊ីដ្រាតកម្មក្នុងអង្គធាតុរឹងជាក្រោមអាស្រ័យលើលំនឹងនៃថាមពលបណ្តាញនិងថាមពលអ៊ីដ្រាតកម្មអ៊ីយ៉ុង ។ ថាមពលបណ្តាញបានពីទំនាញអេឡិចត្រូស្តាទិចរវាងកាចុងនិងអាញ៉ុង ។ ក្រោមដែលមានដង់ស៊ីតេបន្ទុកកាន់តែខ្ពស់ នោះវាមានថាមពលបណ្តាញកាន់តែធំ ។ ដូចនេះ ប្រសិនបើថាមពលបណ្តាញធំ វាធ្វើឱ្យបាត់បង់តែអ៊ីដ្រាតកម្មលើកំណកក្រោមដើម្បីផលអ៊ីយ៉ុងអានីយ៉ុងតូចៗ (មានដង់ស៊ីតេខ្ពស់) ។ ប៉ុន្តែ ថាមពលអ៊ីដ្រាតកម្មអាស្រ័យលើទំនាញរវាងអ៊ីយ៉ុងនិងម៉ូលេគុលទឹកដែលប៉ូលែនៅជុំវិញ ។ កត្តាចម្បងមួយដែលផ្តល់នៅទំនាញអ៊ីយ៉ុង-ឌីប៉ូលខ្លាំង គឺដង់ស៊ីតេបន្ទុកនៃអ៊ីយ៉ុង ។ ក្នុងការដណ្តើមអ៊ីយ៉ុងគ្នានេះយើងឃើញថាប្រសិនបើដង់ស៊ីតេបន្ទុកអ៊ីយ៉ុងខ្ពស់ ជាធម្មតាមានទំនោររក្សាទុកនូវម៉ូលេគុលទឹកជុំវិញវាទាំងអស់ ឬមួយផ្នែកនៃផាសអង្គធាតុរឹង ។ ប៉ុន្តែ អំបិលនៃអ៊ីយ៉ុងមានបន្ទុកទាបមានទំនោរគ្មានម៉ូលេគុលទឹកនៃអ៊ីដ្រាតកម្ម ។

ដូចដែលយើងបាននិយាយពីខាងដើមហើយថា លោហៈអាល់កាឡាំងមានតម្លៃដង់ស៊ីតេបន្ទុកទាប បើប្រៀបធៀបនឹងលោហៈដទៃទៀត។ ដូចនេះយើងអាចដឹងថា អំបិលរឹងនៃលោហៈអាល់កាឡាំងភាគច្រើនគ្មានទឹកនៃអ៊ីដ្រាតកម្ម។ តម្លៃដង់ស៊ីតេបន្ទុកនៃអ៊ីយ៉ុងលីចូម និងសូដ្យូម គឺធំល្មមគ្រប់គ្រាន់ដើម្បីបង្កើតអំបិលអ៊ីដ្រាតខ្លះ។ ឧទាហរណ៍ៈ លីចូមអ៊ីដ្រុកស៊ីត ដែលមានទំរង់អុកតាអ៊ីដ្រាត ($LiOH.8H_2O$)។ ដោយសារអំបិលនៃលោហៈប៉ូតាស្យូម រុយប៊ីដ្យូម និងសេស្យូមមានដង់ស៊ីតេបន្ទុកទាបជាងគេក្នុងពួកលោហៈ មានចំនួនអំបិលតិចតួចដែលមានទឹកនៃអ៊ីដ្រាតកម្ម។

**តារាង 11.3 អង់តាល់ពីអ៊ីដ្រាតកម្មនៃអ៊ីយ៉ុងលោហៈអាល់កាឡាំង**

| អ៊ីយ៉ុង | អង់តាល់ពីអ៊ីដ្រាតកម្ម ($kJ.mol^{-3}$) |
|---|---|
| $Li^+$ | 519 |
| $Na^+$ | 406 |
| $K^+$ | 322 |
| $Rb^+$ | 301 |
| $Cs^+$ | 276 |

លោហៈដែលមានដង់ស៊ីតេទាបមានការប្រែប្រួលនូវអង់តាល់ពីអ៊ីដ្រាតកម្ម ក្នុងចំណោមលោហៈអាល់កាឡាំង ( តារាង 11.3 )។ តម្លៃទាំងនេះទាបណាស់ បើប្រៀបធៀបនឹងអ៊ីយ៉ុង $Mg^{2+}$ គឺ 1920 $kJ.mol^{-1}$ ហើយតម្លៃទាំងនេះថយចុះពីលើចុះក្រោមនៅពេលដែលកាំកើនពីលើចុះក្រោមក្នុងក្រុម។

**គ. ពណ៌អណ្តាតភ្លើង**

លោហៈអាល់កាឡាំងនីមួយៗមានពណ៌អណ្តាតភ្លើងផ្សេងៗគ្នានៅពេលគេយកអំបិលនៃលោហៈទាំងនោះទៅដុត ( តារាង 11.4 )។

**តារាង 11.4 លោហៈអាល់កាឡាំង និងពណ៌អណ្តាតភ្លើងរបស់វា**

| លោហៈ | ពណ៌ |
|---|---|
| លីចូម | ក្រហមជាំ |
| សូដ្យូម | លឿង |
| ប៉ូតាស្យូម | ផ្កាឈូកខ្ចី |
| រុយប៊ីដ្យូម | ក្រហមស្វាយ |
| សេស្យូម | ខៀវ |

ក្នុងដំណើរការនេះ ថាមពលបានពីប្រតិកម្មចំហេះនៃឥន្ធនៈត្រូវបានប្រគល់ឱ្យអំបិលលោហៈដែលត្រូវបានដាក់ចូលក្នុងអណ្ដាតភ្លើង។ ការប្រែប្រួលនេះកើតឡើងដោយសារអេឡិចត្រុងក្នុងអាតូមលោហៈអាល់កាឡាំងកើនទៅភាពភ្ញោចរបស់វា។ ថាមពលត្រូវបានបញ្ចេញជាកាំរស្មីអាចមើលឃើញនៅពេលអេឡិចត្រុងត្រឡប់ទៅភាពគ្រឹះវិញ។ លោហៈអាល់កាឡាំងនីមួយៗត្រូវប្រឈមនឹងការផ្ទេរអេឡិចត្រុងយថាប្រភេទណាមួយរបស់ពួកវា។ ឧទាហរណ៍: ពណ៌លឿងនៃសូដ្យូមបានពីថាមពល (ផុតុង) ដែលបញ្ចេញនៅពេលអេឡិចត្រុងលោតពីអរបីតាល់ $3p^1$ ទៅអរបីតាល់ $3s^1$ របស់អាតូមសូដ្យូមណឺតមួយ។ អ៊ីយ៉ុងនោះត្រូវបានទទួលអេឡិចត្រុងវ៉ាឡង់របស់វា ពីប្រតិកម្មចំហេះក្នុងអណ្ដាតភ្លើង (រូបភាព 11.1)។

3p _____ 3p __↑__ 3p _____

អេឡិចត្រុង → ពីអណ្ដាតភ្លើង ថាមពលបញ្ចេញ → ជាពន្លឺពណ៌លឿង

3s _____ 3s _____ 3s __↑__

**រូបភាពទី 11.1 ក្នុងអណ្ដាតភ្លើងអ៊ីយ៉ុងសូដ្យូម (a) ទទួលបានមួយអេឡិចត្រុងក្នុងអរបីតាល់ 3p (b)។ នៅពេលអេឡិចត្រុងលោតពីលក្ខណៈលំញ័រ 3p ទៅលក្ខណៈដើម 35(c) ថាមពលបញ្ចេញជាពន្លឺពណ៌លឿង។**

## ១១.៣ កម្រិតរលាយនៃអំបិលលោហៈអាល់កាឡាំង

កម្រិតរលាយនៃអំបិលលោហៈអាល់កាឡាំងធ្វើឱ្យពួកវាមានប្រយោជន៍យ៉ាងខ្លាំង ក្នុងមន្ទីរពិសោធគីមី។ ទោះវាជាអាញ៉ុងនីត្រាត ផូស្វាត ឬក្លរួដែលយើងត្រូវការ យើងអាចចាត់ទុកថាអំបិលនៃលោហៈអាល់កាឡាំងអាចឱ្យយើងធ្វើសូលុយស្យុងអាញ៉ុងដែលយើងត្រូវការបានដែរ។ ផ្ទុយទៅវិញកម្រិតរលាយរបស់ពួកវាមានតម្លៃខុសៗគ្នាខ្លាំងណាស់ ឧទាហរណ៍: សូលុយស្យុងឆ្អែតនៃលីចូមក្លរួមានកំហាប់ 14 $mol.L^{-1}$ ដែលសូលុយស្យុងឆ្អែតនៃលីចូមកាបូណាតមានកំហាប់ត្រឹមតែ 0.18 $mol.L^{-1}$។

---

### បឹង MONO

បឹងនៅកាលីហ្វញ៉ានេះមានតែមួយនៅក្នុងលោក ហើយភាពអស្ចារ្យនេះដោយសារតែលក្ខណៈគីមីរបស់វា។ បឹងនេះហ៊ុំព័ទ្ធដោយភ្នំ និងភ្នំភ្លើង ដែលគ្មានច្រកចេញ ដូចនេះការបាត់បង់ទឹកគឺដោយសារតែការហួត។ បឹងនេះជាបឹងចាស់ជាងគេបំផុតនៅអាមេរិកខាងជើង ដែលមានអាយុយ៉ាងតិចក៏ 760.000 ឆ្នាំដែរ។ កំឡុងពេលនោះអំបិល ដែលរលាយត្រូវបានជ្រាបចេញពីផ្ទៃជុំវិញ និងប្រភពទឹកក្រោមដី។

ហើយវាមានផ្ទៃប្រហែល $180km^2$ ជាមួយជម្រៅមធ្យមប្រហែល 20m ។ គេបាន គណនាឃើញថា វាមានអំបិលរលាយក្នុងនោះប្រហែល $2.8.10^8$ តោន ។



**រូបលើបង្ហើញពីសសរថ្មកំពូលស្រួច tufa នៅបឹង Mono នៅរដ្ឋ Utah សហរដ្ឋអាមេរិក**

ក្នុងបឹងធំផ្សេងនៅរដ្ឋ Utah មានភាគច្រើនជាអំបិលសូដ្យូមក្លរួ ប៉ុន្តែនៅឯបឹង Mono មានអំបិលរលាយជាច្រើនប្រភេទដូចជាអំបិលសូដ្យូម និងប៉ូតាស្យូម រួមទាំងក្លរួ ស៊ុលផាត អ៊ីដ្រូសែនកាបូណាត បរ៉ាត និងបរិមាណតិចតួចនៃអ៊ីយ៉ុងភ្លុយអរួ អ៊ីយ៉ូដួ អាសេណាត និងអ៊ីយ៉ុងតង់ស្តាត។ ហើយក៏មានអ៊ីយ៉ុងនៃលោហៈផ្សេងទៀតដែរ ដូចជាកាល់ស្យូម ម៉ាញេស្យូម និងស្ត្រង់ចូម។ ដោយវាសំបូរអ៊ីយ៉ុង $HCO_3^-$ និង $CO_3^{2-}$ នាំឱ្យ pH របស់បឹងនេះប្រហែល 10។ ទោះបីជាមាឌនៃសមាសភាគក្នុងនោះត្រូវបានគេដឹង ក៏នៅតែមានការរកឃើញនូវអន្តរកម្មនៃអ៊ីយ៉ុង និងសមាសភាគផ្សេងៗទៀតតាមជម្រៅ និងរដូវ។

សសរថ្ម tufa ជាលក្ខណៈពិសេសបំផុតនៃបឹងនេះ។ ពួកវាកើតឡើងនៅពេលទឹកក្រោមដីដែលមានសំបូរអ៊ីយ៉ុងកាល់ស្យូមផ្សំជាមួយអ៊ីយ៉ុងកាបូណាតរបស់ទឹកបឹង។ ដូចនេះ សសរថ្មបញ្ជាក់ពីទីតាំងនៃទឹកចេញពីក្រោមដី។ ភាពសំបូរនៃអ៊ីយ៉ុងពីរប្រភេទនោះក្នុងទឹកបឹង ធ្វើឱ្យកករកាល់ស្យូមកាបូណាតកើតឡើងនៅបាតបឹង។ សសរថ្មនោះកើតឡើងតែនៅក្នុងទឹក ដូចនេះសសរថ្មដែលអាចមើលឃើញសព្វថ្ងៃនេះត្រូវបានមកពីការស្រកចុះនៃកំរិតទឹកតាំងពីឆ្នាំ 1941។ នៅពេលនោះ ទឹកត្រូវបានគេប្រើដើម្បីផ្គត់ផ្គង់លើផ្នែកកសិកម្ម និងការប្រើប្រាស់ផ្សេងៗទៀតនៅក្នុងរដ្ឋ។

មិនមែនតែលក្ខណៈគីមីជាយថាប្រភេទនោះទេ សម្រាប់បឹងនេះ តែក៏ជាអេកូឡូស៊ីដែរ។ ដោយសារ pH និងកំហាប់អំបិលរលាយខ្ពស់ ដូចនេះភាវៈរស់ដែលអាចរស់បានក្នុងទឹកនេះ គឺមានតែ សារាយបង្កងទឹកប្រៃ និងរុយខ្មៅៗ។ សារាយជាចំនីរបស់ហ្វូងរុយខ្មៅៗដែលហោះនៅជុំវិញបឹងនេះ ដែលចំណាយពេលពីរវដ្តក្នុងចំណោមបីវដ្តជីវិតរបស់ពួកវាក្នុងទឹកបឹង។ រុយទាំងនេះសំបូរទៅដោយខ្លាញ់ និងប្រូតេអ៊ីនដែលជាប្រភពអាហារដ៏សំខាន់សម្រាប់បក្សីដែលមកពីគ្រប់ទិសទីបន្តដំណើររបស់ពួកវាទៀត។ ជាក់ស្តែងបឹងនេះជាឋានប្រព័ន្ធដ៏សំខាន់មួយក្នុងលោក។

នៅពេលដែលមានការប្រែប្រួលនៃកម្រិតទឹកដែលមានការឡើងចុះ ធ្វើឱ្យវាសល់បរិមាណតិចប្រហែល 50% ក្នុងឆ្នាំ1982 ប្រៀបនឹងឆ្នាំ 1941។ ឯការឡើងចុះនេះខ្លាំងពេក ធ្វើឱ្យកំហាប់អ៊ីយ៉ុងឡើងខ្ពស់ដែលសំលាប់ភាវៈរស់នៅក្នុងបឹងនោះ និងបក្សីផងដែរ។ ប៉ុន្តែបឹងនេះត្រូវបានគេជ្រើសរើសជាប្រភពទឹករបស់ជាតិដ៏មហាសាល។ នេះមានន័យថាចំណុះទឹកត្រូវបន្ថែមវិញរហូតដល់ 70% នៃមាឌពីមុន (បច្ចុប្បន្ននេះ តួរលេខត្រូវបង្ហាញថាសល់ 60%) ហើយមាឌនេះនឹងត្រូវរក្សារហូត។

បច្ចុប្បន្នបឹង Mono ជាបឹងចាប់អារម្មណ៍មួយនៃអ្នកវិទ្យាសាស្ត្រ NASA សម្រាប់សិក្សាប្រតិកម្មគីមីនៅភពអង្គារ។ នៅភពអង្គារមានបាតបឹងចាស់ៗស្ងួតជាច្រើនដែលគេជឿថាអាចមានលក្ខណៈស្រដៀងនឹងបឹង Mono ដូច្នេះប្រហែលជាមានប្រភេទភាវៈរស់ស្រដៀងដែរ។ គឺមីវិទូតារាសាស្ត្រចង់បានរូបថតច្បាស់លាស់នៃបាតបឹងនៅភពអង្គារដើម្បីដឹងថាវាមានសសរថ្ម Tufa ដែលបង្ហាញពីដំណើរការគីមីដូចគ្នា ឬអត់។

---

បំរែបំរួលនេះបង្ហាញពីកំរិតរលាយនៃសូដ្យូមអាឡូសែន (តារាង 11.5)

ដើម្បីពន្យល់ពីបំរែបំរួលនៃកម្រិតរលាយយើងត្រូវមើលពីវដ្តថាមពលដែលទាក់ទងក្នុងការបង្កើតសូលុយស្យុងបីអង្គធាតុរឹង។ កម្រិតរលាយនៃសមាសធាតុគឺអាស្រ័យលើបំរែបំរួលអង់តាល់ពី

**តារាង 11.5 កំរិតរលាយនៃសូដ្យូមអាឡូសែន**

| សមាសធាតុ | កំរិតរលាយ ($mol.L^{-1}$) |
|---|---|
| NaF | 0.99 |
| NaCl | 6.2 |
| NaBr | 9.2 |
| NaI | 12.3 |

(ថាមពលបណ្តាញ និងអង់តាល់ពីនៃអ៊ីដ្រាតកម្មកាចុង និងអាញ៉ុង) ដែលទាក់ទងនឹង បំរែបំរួលអង់ត្រូពី (រូបទី 11.2)។ ដើម្បីឱ្យអំបិលរលាយ ថាមពលសេរី $\Delta G^o$ ត្រូវមានសញ្ញាអវិជ្ជមានដែល:

$$\Delta G^o = \Delta H^o - T\Delta s^o$$




**រូបទី 11.2 វដ្តអង់តាល់ពី (a) និងវដ្តអង់ត្រូពី (b) ចំពោះសូលុយស្យុងនៃសមាសធាតុអ៊ីយ៉ូនិច។ $M^+$ ជាអ៊ីយ៉ុងលោហៈអាល់កាឡាំងហើយ $X^-$ ជាអាញ៉ុង។**

ប្រសិនយើងមើលអង់តាល់ពីក្នុងតារាង11.6 យើងឃើញថាសូដ្យូមអាឡូសែននីមួយៗ មានថាមពលបណ្តាញស្មើនឹងអង់តាល់ពីអ៊ីដ្រាតកម្មកាចុងបូកនឹងអង់តាល់ពីអ៊ីដ្រាតកម្មអាញ៉ុង។ ជាក់ស្តែងតម្លៃខុសគ្នានៃពិសោធន៍នេះធំជាងតម្លៃខុសគ្នាតាមការគណនាទៅទៀត។ ដូចនេះយើងអាចនេះយាយបានថាថាមពលបណ្តាញ និងអង់តាល់ពីអ៊ីដ្រាតកម្ម គឺស្មើគ្នា។

**តារាង 11.6 កត្តាអង់តាល់ពីក្នុងសូលុយស្យុងសូដ្យូមអាឡូសែន**

| សមាសធាតុ | ថាមពលបណ្តាញ (kJ.mol$^{-1}$) | អង់តាល់ពីអ៊ីដ្រាតកម្ម (kJ.mol$^{-1}$) | បម្រែបម្រួលអង់តាល់ពី (kJ.mol$^{-1}$) |
|---|---|---|---|
| NaF | +930 | -929 | +1 |
| NaCl | +788 | -784 | +4 |
| NaBr | +752 | -753 | -1 |
| NaI | +704 | -713 | -9 |

នៅពេលយើងគណនាបំរែបំរួលអង់ត្រូពីក្នុងតារាង 11.7 យើងឃើញថា អំបិលទាំងអស់លើកលែងសូដ្យូមភ្លុយអរូ អង់ត្រូពីដែលកើនឡើងដោយអ៊ីយ៉ុងនៅពេលពួកវាចេញពីបណ្តាញក្រាម គឺធំជាងអង់ត្រូពីដែលបាត់បង់នៅពេលអ៊ីយ៉ុងនៃខុស្ទ័នទាំងនេះរងអ៊ីដ្រាតកម្មក្នុងសូលុយស្យុង។ ដើម្បីទទួលបានបំរែបំរួលថាមពលសេរី សំខាន់ដំណើរការសូលុយស្យុង យើងត្រូវបញ្ចូលបំរែបំរួលប្រព័ន្ធដ៏តូចទាំងពីរនេះចូលគ្នា គឺអង់តាល់ពីនិងអង់ត្រូពី។

**តារាង 11.7 កត្តាអង់ត្រូពីក្នុងសូលុយស្យុងសូដ្យូមអាឡូសែនជាតំលៃ** $T\Delta s$

| សមាសធាតុ | អង់ត្រូពីបណ្តាញ (kJ.mol$^{-1}$) | អង់ត្រូពីអ៊ីដ្រាតកម្ម (kJ.mol$^{-1}$) | បំរែបំរួលអង់ត្រូពី (kJ.mol$^{-1}$) |
|---|---|---|---|
| NaF | +72 | -74 | -2 |
| NaCl | +68 | -55 | +13 |
| NaBr | +68 | -50 | +18 |
| NaI | +68 | -45 | +23 |

| តារាង 11.8 | បំរែបំរួលថាមពលសេរីពីការគណនារបស់សូលុយស្យុងសូដ្យូមអាឡូសែនួ | | |
|---|---|---|---|
| សមាសធាតុ | បំរែបំរួលអង់តាល់ពី (kJ.mol$^{-1}$) | បំរែបំរួលអង់ត្រូពី (kJ.mol$^{-1}$) | បំរែបំរួលថាមពលសេរី (kJ.mol$^{-1}$) |
| NaF | +1 | -2 | +3 |
| NaCl | +4 | +13 | -9 |
| NaBr | -1 | +18 | -19 |
| NaI | -9 | +23 | -32 |

ថាមពលសេរីបានពីការគណនាផ្តល់នូវបំរែបំរួលស្របទៅនឹងកម្រិតរលាយ ដែលបានវាស់ក្នុងតារាង 11.8 ។ លើសពីនេះ បើយើងដាក់អាញ៉ុងនៃអំបិលមួយជាមួយកាចុងលោហៈអាល់កាឡាំងផ្សេងទៀតជាអនុគមន៍នឹងកាំអ៊ីយ៉ូនិចនៃអ៊ីយ៉ុងលោហៈអាល់កាឡាំង យើងទទួលបានខ្សែកោងដ៏រលូន។ ខ្សែកោងនេះអាចមានមេគុណប្រាប់ទិសវិជ្ជមាន ឬអវិជ្ជមាន។ ដើម្បីបង្ហាញពីបំរែបំរួលបែបនេះ កម្រិតរលាយនៃលោហៈអាល់កាឡាំងភ្លុយអរួ និង អ៊ីយ៉ូដួ ត្រូវបានបង្ហាញក្នុងរូប 11.3 ។

**រូបទី 11.3**




យើងអាចយល់ពីខ្សែកោងទាំងពីរក្នុងរូប 11.3 ដោយផ្តោតលើថាមពលបណ្តាញ។ ទោះបីជាមានថាមពលបណ្តាញដ៏ខ្លាំងមួយលើបន្ទុកអ៊ីយ៉ូនិចក៏ដោយ ប៉ុន្តែវាមានទំនាក់ទំនងផ្សេងទៀតទៅនឹងកាំកាចុង ឬអាញ៉ុង ដែលការមិនស៊ីគ្នានៃទំហំអ៊ីយ៉ូនិចរូបទី 11.3 នឹងនាំឱ្យវាមានថាមពលបណ្តាញទាបជាងថាមពលបណ្តាញ ដែលរំពឹងទុក។ តារាង 11.9 បង្ហាញពីកាំអ៊ីយ៉ូនិចនៃកាចុងលីចូម និងសេស្យូម និងអាញ៉ុងភ្លុយអរួ និងអ៊ីយ៉ូដួ។ ដូចនេះលីចូលអ៊ីយ៉ូដួ ដែលក្នុងនោះមានអ៊ីយ៉ុងមានទំហំខុសគ្នាខ្លាំង រលាយខ្លាំងជាងលីចូមភ្លុយអរួ ដែលអ៊ីយ៉ុងរបស់វាមានទំហំប្រហែលគ្នា។ ផ្ទុយទៅវិញ សេស្យូមដែលមានទំហំអ៊ីយ៉ុងប្រហែលគ្នារលាយតិចជាងសេស្យូមភ្លុយអរួ ដែលមានទំហំអ៊ីយ៉ុងខុសគ្នាខ្លាំង។

| តារាង 11.9 | កាំអ៊ីយ៉ូនិច | | |
|---|---|---|---|
| កាចុង | កាំ (pm) | អាញ៉ុង | កាំ (pm) |
| $Li^+$ | 73 | $F^-$ | 119 |
| $Cs^+$ | 181 | $I^-$ | 206 |

## ១១.៤ លីចូម

**លីចូម**មានដង់ស៊ីតេ(0.53g.cm$^{-3}$)ប្រហែលពាក់កណ្តាលទឹក តែមានដង់ស៊ីតេតូចជាងលោហៈផ្សេងទៀត។ ដោយដង់ស៊ីតេស្រាលរបស់វាធ្វើឱ្យលីចូមអាចប្រើជាសំលោហៈក្នុងយានអវកាស។ ឧទាហរណ៍: សំលោហៈ LA 141 ដែលមានលីចូម 14% អាលុយមីញ៉ូម 1% និងម៉ាញេស្យូម 85% ហើយមានដង់ស៊ីតេ 1.35 g.cm$^{-3}$ ប្រហែលពាក់កណ្តាលនៃដង់ស៊ីតេអាលុយមីញ៉ូមប៉ុណ្ណោះ ដែលជាលោហៈមានដង់ស៊ីតេស្រាលគេនិយមប្រើច្រើនជាងគេ។

លោហៈនេះមានលក្ខណៈផ្លេកដូចប្រាក់ ប៉ុន្តែពេលគេដាក់វាក្នុងសំណើមខ្យល់វាប្រែជាពណ៌ខ្មៅ។ ដូចជាលោហៈអាល់កាឡាំងផ្សេងទៀតដែរ លីចូមប្រតិកម្មជាមួយឱអុកស៊ីសែនក្នុងខ្យល់។

$$4Li(s) + O_2(g) \rightarrow 2Li_2O(s)$$

លីចូមជាលោហៈអាល់កាឡាំងតែមួយក្នុងតារាងខួបគីមី ដែលមានប្រតិកម្មជាមួយឱអាសូត។ ការផ្តាច់សម្ព័ន្ធបីជាន់ក្នុងម៉ូលេគុលឱអាសូតត្រូវការថាមពល 943 kJ.mol$^{-1}$ ។ ដើម្បីឱ្យថាមពលនេះមានតុល្យភាព ថាមពលបណ្តាញនៃផលិតផលត្រូវតែខ្ពស់។ ក្នុងចំណោមលោហៈអាល់កាឡាំងមានតែអ៊ីយ៉ុងលីចូមមានដង់ស៊ីតេបន្ទុកធំជាងគេក្នុងក្រុម អាចបង្កើតនីទ្រូ ដែលមានថាមពលបណ្តាញខ្ពស់:

$$6Li(s) + N_2(g) \rightarrow 2Li_3N(s)$$

នីទ្រូសកម្មខ្លាំងណាស់ ហើយវាបង្កើតបានអាម៉ូញ៉ាក់ពេលថែមទឹក

$$Li_3N(s) + 3H_2O(l) \rightarrow 3LiOH(aq) + NH_3(g)$$

លីចូមរាវត្រូវបានគេដឹងថាជាធាតុដែលកាត់។ ឧទាហរណ៍: បើភាគសំណាកលីចូមរលាយក្នុងដបកែវមួយ នោះវានឹងមានប្រតិកម្មដោយឯកឯងជាមួយកែវនោះបណ្តាលឱ្យធ្លុះ ហើយមានបញ្ចេញនូវពន្លឺពណ៌សលាយបៃតងស្រាលយ៉ាងខ្លាំងក្លាបំផុត។ ម្យ៉ាងទៀត អ៊ីយ៉ុងលីចូមមានប៉ូតង់ស្យែលរេដុកស្តង់ដាអវិជ្ជមានធំជាងធាតុផ្សេង :

$$Li^+(aq) + e^- \rightarrow Li(s) \qquad E^o = -3.05V$$

លោហៈនេះបញ្ចេញថាមពលខ្លាំងជាងធាតុផ្សេងទៀត ពេលវារងអុកស៊ីតកម្ម ទៅជាអ៊ីយ៉ុងរបស់វា (+3.05V)។

ក្នុងលោហៈអាល់កាឡាំង លីចូមមិនសូវមានប្រតិកម្មជាមួយទឹកទេ។ ប៉ុន្តែយើងមិនត្រូវច្រឡំពីភាពកើតឡើងឯកឯងនៃទែម៉ូឌីណាមិចដែលអាស្រ័យនឹងបំរែបំរួលថាមពលសេរី ជាមួយល្បឿននៃប្រតិកម្មដែលអាស្រ័យនឹងកំពស់នៃថាមពលសកម្ម។ ក្នុងករណីពិសេសមួយនេះយើងត្រូវគិតថា ថាមពលសកម្មសម្រាប់ប្រតិកម្មជាមួយទឹកចំពោះលីចូម គឺធំជាងលោហៈអាល់កាឡាំងដទៃទៀត។ នោះគួរមិនឱ្យភ្ញាក់ផ្អើលទេ ដោយសារលីចូមមានថាមពលបណ្តាញធំជាងគេក្នុងក្រុមលោហៈអាល់កាឡាំង ហើយព្រោះអុកស៊ីតកម្ម ឬអ៊ីដ្រាតកម្មត្រូវការការគេចពីបណ្តាញ ដូច្នេះថាមពលសកម្មរបស់វា គឺខ្ពស់ជាងគេដែរ។

ការប្រើប្រាស់ក្នុងឧស្សាហកម្មធំៗនៃលីចូម គឺនៅក្នុងខ្លាញ់ម៉ាស៊ីន។ ជាក់ស្ដែងក្នុងខ្លាញ់នៅក្នុងគ្រឿងម៉ាស៊ីនមានខ្លាញ់លីចូមច្រើនជាង60%។ សមាសធាតុដែលប្រើនេះគឺលីចូមស្តេអារ៉ាត ($C_{17}H_{35}COOLi$) ត្រូវបានរលាយជាមួយប្រេងដើម្បីឱ្យក្លាយជាលក្ខណៈមិនជ្រាបទឹក ហើយមិនកកនៅសីតុណ្ហភាពត្រជាក់ និងមានស្ថេរភាពនៅសីតុណ្ហភាពខ្ពស់។

ដោយសារអ៊ីយ៉ុងលីចូមមានដង់ស៊ីតេបន្ទុកធំ នេះអាចពន្យល់ហេតុអ្វីលក្ខណៈគីមីរបស់វាខុសពីធាតុផ្សេងទៀតក្នុងក្រុម។ ជាពិសេសលក្ខណៈគីមីសរីរាង្គលោហៈនៃលីចូម ដែលសម្ព័ន្ធវាជាសម្ព័ន្ធកូវ៉ាឡង់។ សូម្បីតែចំពោះអំបិលធម្មតាដូចជា លីចូមក្លរួ កម្រិតរលាយដ៏ខ្លាំងរបស់វាក្នុងអង្គធាតុរំលាយជាច្រើនដែលមិនសូវប៉ូលែ ជាពិសេសអេតាណុល និងអាសេតូន បង្ហាញថាវាមានសម្ព័ន្ធកូវ៉ាឡង់ក៏រិតខ្ពស់។ សមាសធាតុសរីរាង្គលោហៈមួយទៀតគឺប៊ុយទីលលីចូម ($LiC_4H_9$) ជាសារធាតុសំខាន់មួយក្នុងគីមីសរីរាង្គ។ វាត្រូវបានគេរៀបចំឱ្យប្រតិកម្មរវាងលោហៈលីចូម និងក្លរ៉ូប៊ុយតាន ($C_4H_9Cl$) ដែលមានអង្គធាតុរំលាយជាអ៊ីដ្រូកាបួដូចជាអិចសាន ($C_6H_{12}$):

$$2Li(s) + C_4H_9Cl(C_6H_{12}) \rightarrow LiC_4H_9(C_6H_{12}) + LiCl(s)$$

បន្ទាប់ពីការច្រោះយកអំបិលលីចូមក្លរួចេញរួចមក គេអាចយកអង្គធាតុរំលាយចេញដោយបំហិត គេបានសូលុយស្យុងប៊ុលទីលលីចូម។ សមាសធាតុនេះត្រូវទុកដាក់ឱ្យបានប្រុងប្រយ័ត្នបំផុត ព្រោះវាអាចឆេះដោយឯកឯងនៅពេលវានៅក្នុងខ្យល់។

## គ. អាគុយលីចូម

លីចូមជាសារធាតុមួយគេប្រើច្រើនជាងគេសម្រាប់ធ្វើអាណូតក្នុងអាគុយទំនើបបច្ចុប្បន្ននេះ។ ដោយវាមានប៉ូតង់ស្យែលរេដុកខ្ពស់ និងអាចផ្ទុកថាមពលមួយខ្នាតក្នុងម៉ាសតិចតួច។ គេនិយមប្រើនៅក្នុងថ្មពិលតិចតួចដែលផ្តល់ប៉ូតង់ស្យែលខ្ពស់។ ដោយសារតែលីចូមមានដង់ស៊ីតេ 1/20 នៃសំណដែលធ្វើឱ្យការរៀបចំអាគុយស្រាលជាងដូចនេះនៅអនាគតប្រហែលគេប្រើលីចូមជំនួសសំណក្នុងអាគុយសាកសម្រាប់ យានយន្តដែលប្រើអគ្គិសនី។

អាគុយលីចូមកំពុងត្រូវក្លាយជាអាគុយពេញនិយមប្រើ ប៉ុន្តែជាក់ស្តែងវាមានច្រើនប្រភេទណាស់។ អាគុយដែលមានអ៊ីយ៉ុងលីចូមអាចសាកឡើងវិញបានត្រូវបានគេប្រើសម្រាប់កុំព្យូទ័រយួរដៃ ឬទូរស័ព្ទដៃ។ នៅផ្នែកអាណូតនោះមានលីចូមកូបាល់III អុកស៊ីត($LiCoO_2$) ឯផ្នែកកាតូតជាក្រាភីត ហើយអង្គធាតុរាវសរីរាង្គត្រូវបានគេប្រើជាអេឡិចត្រូលីត។ នៅពេលបញ្ចូលភ្លើងក្នុងអាគុយនេះ នៅកាតូតអ៊ីយ៉ុងលីចូមបានចូលក្នុងសូលុយស្យុង ហើយអេឡិចត្រុងបានបោះបង់។ តុល្យភាពបន្ទុកត្រូវបានរក្សាដោយអ៊ីយ៉ុងកូបាល់ III មួយ ដែលត្រូវរងអុកស៊ីតកម្មជាកូបាល់ IV សម្រាប់អ៊ីយ៉ុងលីចូមនីមួយៗ:

$$LiCoO_2(s) \rightarrow Li_{(1-x)}CoO_2(s) + xLi^+(solvent) + xe^-$$

នៅខាងអាណូតអ៊ីយ៉ុងលីចូមចូលទៅចន្លោះស្រទាប់ក្នុងបណ្ដាញក្រាភីត ហើយរងរេដុកម្ម ក្លាយជាលោហៈលីចូម។ ការចូលនៃអាតូមជាភ្ញៀវបានក្លាយជាអង្គធាតុរឹងជាអ្នកបំរើវិញ ដែលដំណើរការនេះតែធ្វើឱ្យផ្លាស់ប្ដូរតិចតួចនៃទម្រង់របស់វា ដែលគេស្គាល់ថាជាការបញ្ចូលចន្លោះ (Inter calation) ហើយផលិតផលត្រូវបានគេហៅថា សមាសធាតុចន្លោះ :

$$C(s) + xLi^{+}(solvent) + xe^{-} \rightarrow (Li)_{x}C(s)$$

ពេលអាគុយដំណើរការប្រតិកម្មបញ្ច្រាស់ទៅវិញ។

មានអាគុយលីចូមផ្សេងៗទៀតជាច្រើនដែលប្រើអេឡិចត្រូតខុសៗគ្នា។ អេឡិចត្រូត និង អក្សររបស់អាគុយមានដូចជា: ម៉ង់កាណែស(IV)អុកស៊ីត (CR) ប៉ូលីកាបូនម៉ូណូភ្លុយអរូ (BR) វ៉ាណាដ្យូម(V)អុកស៊ីត (VL) និងម៉ង់កាណែសអុកស៊ីត ដែលមានលីចូមអាលុយមីញ៉ូមនៅខាងកាតូត (ML)។ នៅក្នុងអាគុយទាំងនេះភាគច្រើន គេប្រើលោហៈឆ្លងក្នុងប្រព័ន្ធរេដុកដែលយោលនៅចន្លោះចំនួនអុកស៊ីតកម្មទាំងពីរ គឺម៉ង់កាណែសពី IV↔III រីឯវ៉ាណាដ្យូមពី V↔ IV ។

បច្ចុប្បន្នគេពេញនិយមអំពីប្រព័ន្ធអាគុយលីចូម ដែលប្រើ ត្យូនីលក្លរួ ($SOCl_2$)។ អាគុយនេះមានលក្ខណៈផ្ដល់នូវចរន្តអគ្គិសនីខ្ពស់ អាចទុកចិត្តបាន អាចប្រើបានយូរ ទំងន់ស្រាល និងបញ្ចេញនៅថាមពលថេរ។ ប៉ុន្តែ វាមិនអាចបញ្ចូលឡើងវិញបានទេ។ អាគុយប្រភេទនេះត្រូវបានគេប្រើក្នុងយានអវកាស នាវាមុជទឹកសង្គ្រោះ និងមីស៊ីលរបស់នាវាមុជទឹក។ អាគុយលីចូមត្យូនីលក្លរួមានសមាសភាគសំខាន់បីយ៉ាង គឺលោហៈលីចូម ឬអាណូតសំលោហៈលីចូម កាតូតកាបូន និងអេឡិចត្រូលីត $Li^{+}[GaCl_4]^{-}$ ឬ $Li^{+}[AlCl_4]^{-}$ រលាយក្នុងត្យូនីលក្លរួ។ ប្រតិកម្មខាងអាណូត គឺអុកស៊ីតកម្មនៃលីចូមទៅជាអ៊ីយ៉ុងលីចូម :

$$Li(s) \rightarrow Li^{+}(SOCl_2) + e^{-}$$

ហើយត្យូនីលក្លរួរងរេដុកម្មខាងកាតូត

$$2SOCl_2(l) + 4e^{-} \rightarrow 4Cl^{-}(SOCl_2) + SO_2(SOCl_2) + S(SOCl_2)$$

អ៊ីយ៉ុងលីចូម និងអ៊ីយ៉ុងក្លរួមានប្រតិកម្មជាមួយគ្នាលើផ្ទៃកាបូនខាងកាតូតបានលីចូមក្លរួដែលមិនរលាយក្នុងអង្គធាតុរំលាយនេះ:

$$Li^{+}(SOCl_2) + Cl^{-}(SOCl_2) \rightarrow LiCl(s)$$

ដោយនៅខាងកាតូត កន្លែងលីចូមក្លរួកើតឡើងហើយគ្មានសកម្មភាព។ ដូចនេះអាគុយត្រូវឈប់ដំណើរការ ព្រោះលើអេឡិចត្រូតកាបូនត្រូវគ្របដណ្ដប់។ អាគុយផ្សេងមួយទៀត គឺប្រើស៊ុលផួរីលក្លរួ ($SO_2Cl_2$)។ អង្គធាតុរំលាយនេះមានប្រយោជន៍នៅពេលរេដុកម្ម ព្រោះមានផលិតផលតែពីរកើតឡើង គឺអ៊ីយ៉ុងក្លរួ និងស្ពាន់ធ័រឌីអុកស៊ីត :

$$SO_2Cl_2(l) + 2e^{-} \rightarrow 2Cl^{-}(SO_2Cl_2) + SO_2(SO_2Cl_2)$$

អាគុយមួយប្រភេទទៀតជាលីចូម-ស្ពាន់ធ័រឌីអុកស៊ីត។ វាត្រូវបានគេប្រើក្នុងម៉ាស៊ីនស្វ័យប្រវត្ត (defibrillator) ដែលធ្វើឱ្យចង្វាក់បេះដូងជនរងគ្រោះគាំងបេះដូង ឱ្យដើរឡើងវិញ។ អាគុយនេះអាចប្រើនៅសីតុណ្ហភាពចុះដល់ -40ºC ដូចនេះវាក៏ត្រូវបានគេប្រើក្នុងឧបករណ៍ភ្លើងសញ្ញាព្រមានចរាចរណ៍របស់យន្តហោះនៅតំបន់ត្រជាក់។ ស្ពាន់ធ័រឌីអុកស៊ីតរលាយក្នុងអង្គធាតុរលាយសរីរាង្គនៅសម្ពាធ 200-300 kPa។ ដូចគ្រប់អាគុយលីចូម មានដំណើរការអុកស៊ីតកម្មលីចូមនៅខាងអាណូត ប៉ុន្តែក្នុងករណីនេះ ប្រតិកម្មខាងកាតូតជារេដុកម្មនៃស្ពាន់ធ័រឌីអុកស៊ីតទៅជាអ៊ីយ៉ុង $S_2O_4^{2-}$ :

$$2SO_2(solvent)+2e^- \rightarrow S_2O_4^{2-}(solvent)$$

## ១១.៥ សូដ្យូម

លោហៈ**សូដ្យូម**ជាលោហៈអាល់កាឡាំង ដែលមានតម្រូវការខ្ពស់ជាងគេសម្រាប់វិស័យឧស្សាហកម្ម។ ដូចជាលោហៈអាល់កាឡាំងដទៃទៀតដែរ វាមិនមែនជាលោហៈសុទ្ធក្នុងធម្មជាតិទេ ព្រោះតែប្រតិកម្មភាពវាខ្ពស់។ ដោយសារតែកំរិតចម្លងកម្ដៅវាខ្ពស់ លោហៈសូដ្យូមរាវត្រូវបានគេប្រើជាអង្គធាតុរាវចម្លងកម្ដៅក្នុងរេអាក់ទ័រនុយក្លេអ៊ែ ដូចជាក្នុងនាវាមុជទឹក។

គេប្រើលោហៈសូដ្យូមក្នុងការសំយោគចំនួនដ៏ច្រើននៃសមាសធាតុសូដ្យូម ប៉ុន្តែវាមានបំរើបំរាស់សំខាន់ៗពីរយ៉ាង។ ទីមួយ គឺប្រើសម្រាប់រំដោះលោហៈផ្សេងទៀត។ វិធីដ៏ងាយបំផុតដើម្បីទទួលបានលោហៈកម្រដូចជា តូរ្យូម(Th) ស៊ៀកូញ៉ូម(Zr) តង់តាល់(Ta) និងទីតាន(Ti) គឺដោយការធ្វើរេដុកម្មនៃសមាសធាតុរបស់ពួកវាជាមួយសូដ្យូម។ ឧទាហរណ៍: គេទទួលបានទីតានដោយធ្វើរេដុកម្មទីតាន IV ក្លរួជាមួយលោហៈសូដ្យូម:

$$TiCl_4(l)+4Na(s)\rightarrow Ti(s)+4NaCl(s)$$

ដូចនេះគេអាចលាងសូដ្យូមក្លរួចេញពីលោហៈទីតានសុទ្ធ។

បំរើបំរាស់សំខាន់ទីពីរនៃលោហៈសូដ្យូម គឺនៅក្នុងផលិតផលនៃសាំងដែលមានបន្ថែមតេត្រាអេទីលសំណ(TEL)។ ទោះបីជា TEL ត្រូវបានគេហាមឃាត់មិនឱ្យប្រើដោយដាក់ក្នុងសាំងនៅអាមេរិកខាងជើងក៏ដោយ (ព្រោះវាពុលហើយលោហៈសំណធ្វើឱ្យបំពុលបរិស្ថាន) ក៏វានៅតែមានគេធ្វើអាជីវកម្មដ៏សំបើមនៅលើពិភពលោក ដើម្បីបង្កើនកម្លាំងនៃចំហេះអុកតានដែលជាសាំងមានតម្លៃថោក។ ក្នុងការសំយោគ TEL គេប្រើប្រតិកម្មរវាងសំលោហៈសំណនិងសូដ្យូម និងអេទីលក្លរួ:

$$4NaPb(s)+4C_2H_5Cl(g)\rightarrow(C_2H_5)_4Pb(l)+3Pb(s)+4NaCl(s)$$

## ឧស្សាហកម្មនៃសូដ្យូម

សូដ្យូមគឺលោហៈដែលភ្លឺដូចប្រាក់ត្រូវបានគេបង្កើតឡើងដោយ**ដំណើរការ Downs** ដែលក្នុងនោះ NaCl (ចំណុចរលាយ801ºC) ត្រូវបានយកទៅធ្វើអគ្គិសនីវិភាគកម្ដៅអំបិលរលាយ។

អគ្គិសនីវិភាគនេះត្រូវបានគេធ្វើនៅក្នុងប្រអប់រាងស៊ីឡាំងដែលមានអាណូតក្រាភីតនៅចំកណ្តាល ហើយមានដែកថែបជាកាតូតនៅជុំវិញ (រូបទី 11.4) ។ គេបានលាយ NaCl និង $CaCl_2$ ដើម្បីកាត់បន្ថយចំណុចរលាយ និងមានសីតុណ្ហភាពទាបដែលវាត្រូវការដើម្បីដំណើរការ ។ ទោះបីជា $CaCl_2$ មានចំណុចរលាយដល់ 772 $^oC$ ក៏ដោយ តែបើគេលាយNaCl 33% និង $CaCl_2$ 67% គេនឹងបានចំណុចរលាយវាប្រហែល 580$^oC$ ។ វាជាចំណុចរលាយនៃល្បាយដែលទាបជាងមុន ធ្វើឱ្យដំណើរការប្រព្រឹត្តទៅយ៉ាងថោក ។

អេឡិចត្រូតពីរត្រូវបានញែកពីគ្នាដោយសំណាញ់ដែកថែបរាងស៊ីឡាំង ដូចនេះសូដ្យូមដែលរលាយ ដែលអណ្តែតទៅផ្នែកខាងលើនៃកាតូតនឹងត្រូវបានរក្សាទុកឱ្យផុតពីឧស្ម័នក្លរដែលកើតនៅខាងអាណូត ។

$$Na^+(NaCl) + e^- \to Na(l)$$
$$2Cl^-(NaCl) \to Cl_2(g) + 2e^-$$




**FIGURE 11.4** Downs cell.

លោហៈសូដ្យូមដែលផលិតបានមានលាយជាមួយលោហៈកាល់ស្យូមប្រហែល0.2% ។ នៅពេលបញ្ចុះសីតុណ្ហភាពនៃល្បាយដល់ 110$^oC$ ធ្វើឱ្យកាល់ស្យូមកក ហើយលិចចុះទៅក្រោម ។ សូដ្យូមសុទ្ធ (ចំណុចរលាយ98$^oC$)នឹងនៅសល់ជាអង្គធាតុរាវ ហើយគេនឹងបូមចូលទៅក្នុងពុម្ពត្រជាក់ ដែលជាកន្លែងដែលវាក្លាយជាអង្គធាតុរឹង ។

## ១១.៦ ប៉ូតាស្យូម

**ប៉ូតាស្យូម**ជាធាតុវិទ្យុសកម្មខ្សោយដែលមាននៅក្នុងធម្មជាតិ ព្រោះវាមានអ៊ីសូតូបវិទ្យុសកម្មប៉ូតាស្យូម-40 ប្រហែល 0.012% ។ ជាក់ស្តែងការបញ្ចេញវិទ្យុសកម្មក្នុងខ្លួនមនុស្សយើងមួយផ្នែកធំ

បានមកពីអ៊ីសូតូបនេះ ដែលវាមានពាក់កណ្ដាលជីវិត$1.3x10^9$ឆ្នាំ។ អាតូមប៉ូតាស្យូមប្រហែល 89% បំបែកណ្វៃយ៉ូដោយការបោះបង់អេឡិចត្រុងមួយ ហើយ 11% ទៀតបំបែកណ្វៃយ៉ូដោយការចាប់យកអេឡិចត្រុង។

$$^{40}_{19}K \rightarrow ^{40}_{20}Ca + ^{0}_{-1}e$$
$$^{40}_{20}K + ^{0}_{-1}e \rightarrow ^{40}_{18}Ar$$

ការបំបែកពីប៉ូតាស្យូម-40ទៅជាអាកុង-40ជាវិធីមួយនៃការកំណត់អាយុកាលនៃសិលានៅពេលដែលម៉ាក់ម៉ា (ថ្មរាវ) កក ដោយសារអាកុងត្រូវរក្សាទុកនៅក្នុងសិលា។

យើងបានដឹងហើយថា ក៏វិតរលាយនៃអំបិលលោហៈអាល់កាឡាំងសុទ្ធតែជាអំបិលដែលរលាយជាពិសេស ចំពោះអំបិលដែលរលាយតិចជាងគេក៏ដោយសារតែវាមានទំហំអ៊ីយ៉ុងប្រហាក់ប្រហែលគ្នា។ ដូចនេះអាញ៉ុងដែលធំ និងកាចុងនៃលោហៈអាល់កាឡាំងដែលធំ គេទទួលបានអំបិលដែលរលាយតិច។ ឧទាហរណ៍ដូចជាអ៊ីយ៉ុងធំនៃអិចសានីទ្រីតូកូបាល់តាត III ($[Co(NO_2)_6]^{3-}$)។ អំបិលរបស់វាជាមួយលីចូមនិងសូដ្យូមរលាយ ប៉ុន្តែបើជាមួយប៉ូតាស្យូមមិនរលាយទេ ដូចនេះ គេអាចធ្វើតេស្តវាដោយបន្ថែមអ៊ីយ៉ុងសូដ្យូម ឬប៉ូតាស្យូម និងអ៊ីយ៉ុងអិចសានីទ្រីតូកូបាល់តាតIII។ កករពណ៌លឿងស្រាលនឹងបង្ហាញពីវត្តមានអ៊ីយ៉ុងប៉ូតាស្យូមៈ

$$3K^+(aq) + [Co(NO_2)_6]^{3-}(aq) \rightarrow K_3[Co(NO_2)_6](s)$$

អាញ៉ុងដែលធំមួយទៀត ហើយអាចបង្កើតកករជាមួយកាចុងលោហៈអាល់កាឡាំងដែលធំគឺអ៊ីយ៉ុងតេត្រាផេនីលបរ៉ាត $[B(C_6H_5)_4]^-$

$$K^+(aq) + [B(C_6H_5)_4]^-(aq) \rightarrow K[B(C_6H_5)_4](s)$$

## ឧស្សាហកម្មនៃប៉ូតាស្យូម

គេផលិតលោហៈប៉ូតាស្យូមជាជំនួញតាមវិធីគីមី។ ទម្ងើលោហៈនេះតាមអគ្គិសនីវិភាគពុលខ្លាំងណាស់ ព្រោះតែសកម្មភាពគីមីរបស់វាខ្លាំងក្លា។ ដូចនេះគេធ្វើវាតាមវិធីគីមីមួយដោយប្រតិកម្មរវាងលោហៈសូដ្យូម និងអំបិលប៉ូតាស្យូមរលាយនៅ 850 $^oC$ :

$$Na(l) + KCl(l) \rightleftharpoons K(g) + NaCl(l)$$

ទោះបីជាលំនឹងរំកិលទៅខាងឆ្វេង ប៉ុន្តែនៅសីតុណ្ហភាពនេះប៉ូតាស្យូមជាឧស្ម័ន (ចំណុចរំពុះ 766 $^oC$ និងចំណុចរំពុះសូដ្យូម 890 $^oC$)។ ដូចនេះតាមច្បាប់ Le Chatelier ប្រតិកម្មអាចរំកិលទៅខាងស្ដាំដោយបូមឧស្ម័នពណ៌បៃតងនៃប៉ូតាស្យូមចេញពីល្បាយ។

## ១១.៧ អុកស៊ីត

លោហៈភាគច្រើននៅក្នុងតារាងខួបមានប្រតិកម្មជាមួយអុកស៊ីសែន គេទទួលបានអុកស៊ីតដែលមានអ៊ីយ៉ុងអុកស៊ីត ($O^{2-}$) ។ ទោះបីជាយ៉ាងនេះក្តី ចំពោះលោហៈអាល់កាឡាំងមានតែលីចូមទេដែលមានប្រតិកម្មជាមួយអុកស៊ីសែនឱ្យជាអុកស៊ីតធម្មតាៈ

$$4Li(s) + O_2(g) \rightarrow 2Li_2O(s)$$

សូដ្យូមមានប្រតិកម្មជាមួយអុកស៊ីសែន គេទទួលបានសូដ្យូមឌីអុកស៊ីត (2-) ($Na_2O_2$ដែលគេហៅថា សូដ្យូមពែអុកស៊ីត)មានអ៊ីយ៉ុងឌីអុកស៊ីត($O_2^{2-}$ ហៅថាអ៊ីយ៉ុងពែអុកស៊ីត)ៈ

$$2Na(s) + O_2(g) \rightarrow Na_2O_2(s)$$

យើងត្រូវចំណាំថា "2- "បង្ហាញពីបន្ទុកនៅលើអ៊ីយ៉ុង។ បច្ចុប្បន្នយើងប្រើលេខអារ៉ាប់ដាក់ក្នុងវង់ក្រចកដើម្បីដាក់ឈ្មោះឱ្យក្រុម នៅពេលដែលអាញ៉ុងមានច្រើនជាងមួយ។ នេះជាវិធីមួយដែលផ្តល់ដោយសហគមន៍អាមេរិច។

សូដ្យូមឌីអុកស៊ីត (2-) ជាដ្យាម៉ាញេទិច ហើយមានប្រវែងសម្ព័ន្ធរវាងអាតូម O-O ប្រហែល 149pm វែងជាងប្រវែងសម្ព័ន្ធរវាង O-O ក្នុងម៉ូលេគុលអុកស៊ីសែនដែលមានប្រវែងសម្ព័ន្ធត្រឹមតែ 121pm។ យើងអាចពន្យល់ពីលក្ខណៈដ្យាម៉ាញេទិច និងកម្លាំងសម្ព័ន្ធខ្សោយដោយគូរផ្នែកមួយនៃដ្យាក្រាមអរប៊ីតាល់ម៉ូលេគុល ដែលបានបង្ហាញពីអរប៊ីតាល 2p (រូបភាពទី 11.5)។




**រូប 11.5 បង្ហាញការបំពេញអរប៊ីតាល់ម៉ូលេគុលដែលមកពីអរប៊ីតាល 2p របស់អ៊ីយ៉ុងឌីអុកស៊ីត (2-) ដែលធម្មតាគេហៅថាអ៊ីយ៉ុងពែអុកស៊ីត។**

ដ្យាក្រាមនេះបង្ហាញថាមានអរប៊ីតាល់សម្ព័ន្ធបីនិងអរប៊ីតាល់បដិសម្ព័ន្ធពីរ ដែលពេញហើយ។ អេឡិចត្រុងទាំងអស់ត្រូវបានដាក់ជាគូៗ។ **លំដាប់សម្ព័ន្ធ**[1] គឺជា១ មិនមែន២ ដែលជាលំដាប់សម្ព័ន្ធក្នុងម៉ូលេគុលឌីអុកស៊ីសែន។

លោហៈអាល់កាឡាំងបីផ្សេងទៀតមានប្រតិកម្មជាមួយអុកស៊ីសែនបង្កើតជាឌីអុកស៊ីត(1-) (គេហៅថាស៊ុបពែអុកស៊ីត)ដែលមានអ៊ីយ៉ុងប៉ារ៉ាម៉ាញេទិចឌីអុកស៊ីត $O_2^-$

$$K(s) + O_2(g) \rightarrow KO_2(s)$$

ប្រវែងសម្ព័ន្ធរវាងអាតូម O-O ក្នុងអ៊ីយ៉ុងទាំងនេះ(133 pm) ខ្លីជាងក្នុងឌីអុកស៊ីត(2-) ប៉ុន្តែវែងជាងប្រវែងសម្ព័ន្ធក្នុងម៉ូលេគុលរបស់វាបន្តិច។ យើងអាចពន្យល់ប្រវែងសម្ព័ន្ធខុសគ្នានេះដោយការបំពេញអរប៊ីតាល់ម៉ូលេគុល (រូបទី 11.6)។




**រូប 11.6 បង្ហាញការបំពេញអរប៊ីតាល់ម៉ូលេគុលដែលមកពីអរប៊ីតាល 2p របស់អ៊ីយ៉ុងឌីអុកស៊ីត (1-) ដែលធម្មតាគេហៅថាអ៊ីយ៉ុងស៊ុបពែអុកស៊ីត។**

អ៊ីយ៉ុងឌីអុកស៊ីត(1-)មានគូសម្ព័ន្ធបីគូ និងបដិសម្ព័ន្ធមួយគូកន្លះ។ លំដាប់សម្ព័ន្ធបានមកក្នុងអ៊ីយ៉ុងឌីអុកស៊ីសែនគឺ 1½ នៅរវាងលំដាប់សម្ព័ន្ធក្នុងអ៊ីយ៉ុងឌីអុកស៊ីត(2-) និងលំដាប់សម្ព័ន្ធក្នុងម៉ូលេគុលអុកស៊ីសែន។ យើងអាចពន្យល់ពីការបង្កើតនៃអ៊ីយ៉ុងឌីអុកស៊ីត(1-) និងឌីអុកស៊ីត(2-) ដោយសន្មតថាកាចុងដែលប៉ូលែតិច (មានដង់ស៊ីតេបន្ទុកទាប)ធ្វើឱ្យអាញ៉ុងប៉ូលែខ្លាំងមានស្ថេរភាព។

---

[1] លំដាប់សម្ព័ន្ធ $= \frac{1}{2}\left(\text{ចំនួនអេឡិចត្រុងក្នុង អរប៊ីតាល់សសម្ព័ន្ធ} - \text{ចំនួនអេឡិចត្រុងក្នុង អរប៊ីតាល់សមិនបដិសម្ព័ន្ធ}\right)$

លំដាប់សម្ព័ន្ធបញ្ជាក់ពីកំលាំងសម្ព័ន្ធ។ ឧទាហរណ៍ បើសិនជាមានអេឡិចត្រុងពីរក្នុងអរប៊ីតាល់ ម៉ូលេគុលសម្ព័ន្ធ និងគ្មាននៅក្នុងអរប៊ីតាល់ម៉ូលេគុលបដិសម្ព័ន្ធ នោះលំដាប់សម្ព័ន្ធស្មើនឹង ១ ដែល មានន័យថា មានសម្ព័ន្ធកូវ៉ាឡង់មួយ ហើយម៉ូលេគុលនោះមានស្ថិរភាព។ ចូរចំណាំថា លំដាប់សម្ព័ន្ធអាច ជាប្រភាគ ប៉ុន្តែលំដាប់ស្មើសូន្យ (ឬមានតំលៃអវិជ្ជមាន) មានន័យថា សម្ព័ន្ធគ្មានស្ថិរភាពហើយម៉ូលេគុល ក៏មិនអាចមានដែរ។

អុកស៊ីតនៃលោហៈក្រុមទីមួយមានប្រតិកម្មខ្លាំងក្លាជាមួយទឹកឱ្យជាសូលុយស្យុងអ៊ីដ្រុកស៊ីតនៃលោហៈទាំងនោះ។ លើសពីនេះ សូដ្យូមឱអុកស៊ីត(2-)បង្កើតបានអ៊ីដ្រូសែនពែអុកស៊ីត ហើយឱអុកស៊ីត(1-)បង្កើតបានអ៊ីដ្រូសែនពែអុកស៊ីត និងឧស្ម័នអុកស៊ីសែនៈ

$$Li_2O(s) + H_2O(l) \rightarrow 2LiOH(aq)$$
$$Na_2O_2(s) + 2H_2O(l) \rightarrow 2NaOH(aq) + H_2O_2(aq)$$
$$2KO_2(s) + 2H_2O(l) \rightarrow 2KOH(aq) + H_2O_2(aq) + O_2(g)$$

គេប្រើប៉ូតាស្យូមឱអុកស៊ីត(1-)ក្នុងយានអវកាស នាវាមុជទឹក និងឧបករណ៍ប្រើប្រាស់មួយចំនួនដូចជាឧបករណ៍សម្រាប់ដកដង្ហើម ព្រោះវាស្រូបឧស្ម័នកាបូនិច ហើយបញ្ចេញនូវឧស្ម័នអុកស៊ីសែនៈ

$$4KO_2(s) + 2CO_2(g) \rightarrow 2K_2CO_3(s) + 3O_2(g)$$
$$K_2CO_3(s) + CO_2(g) + H_2O(l) \rightarrow 2KHCO_3(aq)$$

## ១១.៨ អ៊ីដ្រុកស៊ីត

អង្គធាតុរឹងអ៊ីដ្រុកស៊ីតនៃលោហៈអាល់កាឡាំងមានពណ៌សថ្លា ដែលស្រូបសំណើមពីក្នុងខ្យល់រហូតពួកវារលាយក្នុងទឹក ដំណើរការនោះគេហៅថា ការស្រូបទឹក (deliquescence)។ ករណីលើកលែងមួយចំពោះលីចូមអ៊ីដ្រុកស៊ីតដែលបង្កើតជាអុកតាអ៊ីដ្រាត ($LiOH.8H_2O$) ដែលមានស្ថិរភាព។ អ៊ីដ្រុកស៊ីតនៃលោហៈទាំងអស់នេះពុលខ្លាំងណាស់ ព្រោះអ៊ីយ៉ុងអ៊ីដ្រុកស៊ីតមានប្រតិកម្មជាមួយប្រូតេអ៊ីនលើស្បែកដោយបំផ្លាញផ្ទៃស្បែក។ សូដ្យូមអ៊ីដ្រុកស៊ីត និងប៉ូតាស្យូមអ៊ីដ្រុកស៊ីតត្រូវបានគេធ្វើជាគ្រាប់ៗគឺដោយប្រើអង្គធាតុរាវចាក់ពុម្ព។ ពេល NaOH និង KOH នោះជាអង្គធាតុរឹង ឬក្នុងសូលុយស្យុងក៏ដោយ ពួកវាស្រូបឧស្ម័នកាបូនិចពីបរិយាកាស។

$$2NaOH(aq) + CO_2(g) \rightarrow Na_2CO_3(aq) + H_2O(l)$$

អ៊ីដ្រុកស៊ីតនៃលោហៈអាល់កាឡាំងជាប្រភពដ៏ងាយស្រួលនៃអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ព្រោះពួកវាងាយរលាយក្នុងទឹក។ នៅពេលគេត្រូវការអ៊ីយ៉ុងអ៊ីដ្រុកស៊ីតជាសារធាតុបន្ទាល់ ប្រភពរបស់វាត្រូវបានជ្រើសរើសដោយអាស្រ័យលើតម្លៃ និងកំរិតរលាយ។ ក្នុងគីមីអសរីរាង្គសូដ្យូមអ៊ីដ្រុកស៊ីត (ស៊ូតរលាក [caustic soda]) ជាប្រភពអ៊ីយ៉ុងអ៊ីដ្រុកស៊ីតដ៏សាមញ្ញមួយ ព្រោះវាជាអ៊ីដ្រុកស៊ីតនៃលោហៈ ដែលថោកជាងគេ។ ប៉ូតាស្យូមអ៊ីដ្រុកស៊ីត (ប៉ូតាសរលាក[caustic potash]) គេចូលចិត្តប្រើក្នុងគីមីសរីរាង្គជាងសូដ្យូម អ៊ីដ្រុកស៊ីត ព្រោះវាមានកំរិតរលាយខ្ពស់ជាងក្នុងអង្គធាតុរំលាយសរីរាង្គ។

### ក. ឧស្សាហកម្មសំយោគសូដ្យូមអ៊ីដ្រុកស៊ីត

សូដ្យូមអ៊ីដ្រុកស៊ីតជាសារធាតុគីមីលំដាប់ទី៦ ដោយសារតែបរិមាណផលិតរបស់វា។ វាត្រូវបានគេរៀបចំឡើងដោយអគ្គិសនីវិភាគទឹកប្រៃ(សូលុយស្យុងសូដ្យូមក្លរួ)។ **ពិលបន្ទះខ័ណ្ឌ**ត្រូវបានគេប្រើដើម្បីផលិតសូដ្យូមអ៊ីដ្រុកស៊ីត។ ក្នុងពិលនេះទឹករងរេដុកម្មទៅជាឧស្ម័នអ៊ីដ្រូសែន ហើយអ៊ីយ៉ុង

អ៊ីដ្រុកស៊ីតខាងកាតូត រីឯអ៊ីយ៉ុងក្លរួរងអុកស៊ីតកម្មជាឧស្ម័នក្លរនៅខាងអាណូត (ទោះជាទឹកខ្លះត្រូវបានរង អុកស៊ីតកម្មជាមួយ អុកស៊ីសែនក៏ដោយ):

$$2H_2O(l) + 2e^- \rightarrow H_2(g) + 2OH^-(aq)$$

$$2Cl^-(aq) \rightarrow Cl_2(g) + 2e^-$$

**រូប 11.7 ពិលបន្ទះខ័ណ្ឌ**




លក្ខណៈពិសេស(រូបទី11.7)នៃពិលនេះគឺបន្ទះខ័ណ្ឌ ដែលការពារអ៊ីយ៉ុងអ៊ីដ្រុកស៊ីតខាងកាតូតពីការមកប៉ះនៃឧស្ម័នក្លរដែលនៅខាងអាណូត។ បន្ទះខ័ណ្ឌនេះមានរន្ធតូចៗល្មមសម្រាប់ឱ្យទឹកអំបិលឆ្លងកាត់។ មុនដំបូងគេត្រូវបានប្រើ asbestos ប៉ុន្តែវាអាចបង្កជម្ងឺមហារីក ដូច្នេះឥឡូវនេះគេប្រើជាសំណាញ់ Teflon។ ពិលនេះប្រើចរន្តអគ្គិសនីខ្ពស់ណាស់គឺនៅចន្លោះពី 30 000 ទៅ 150 000A ។

កំឡុងពេលអគ្គិសនីវិភាគ សូលុយស្យុងខាងកាតូតដែលមានល្បាយសូដ្យូមអ៊ីដ្រុកស៊ីត 11% និងសូដ្យូមក្លរួ 16% ត្រូវបានយកចេញជាបន្តបន្ទាប់។ សូលុយស្យុងទទួលបានត្រូវយកទៅរំហួត ដែលអាចធ្វើឱ្យសូដ្យូមក្លរួកំណកជាក្រោមព្រោះវារលាយតិចជាងសូដ្យូមអ៊ីដ្រុកស៊ីត។ ផលិតផលចុងក្រោយ គឺសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត50% ហើយសូដ្យូមក្លរួប្រហែល1%។ សមាសភាគនេះ គេអាចទទួលយកបានសម្រាប់ឧស្សាហកម្ម។

## ខ. បំរើបំរាស់សូដ្យូមអ៊ីដ្រុកស៊ីត

ផលិតផលសូដ្យូមអ៊ីដ្រុកស៊ីតប្រហែល 30% ត្រូវបានគេប្រើជាធាតុបន្ទាល់ក្នុងរោងចក្រសមាសធាតុគីមីសរីរាង្គ ហើយប្រហែល 20% ប្រើសម្រាប់សំយោគសមាសធាតុរ៉ែផ្សេងទៀត។ រីឯ 20% ទៀតប្រើក្នុងឧស្សាហកម្មផលិតក្រដាស និងសល់ 30% ទៀតសម្រាប់ប្រើប្រាស់ផ្សេងៗទៀត។

សូដ្យូមអ៊ីដ្រុកស៊ីតជាបាសដ៏សំខាន់មួយក្នុងមន្ទីរពិសោធគីមី។ វាក៏ត្រូវគេប្រើច្រើនផងដែរនៅតាមផ្ទះជាទឹកក្បុង។ ការប្រើប្រាស់ផ្ទាល់ភាគច្រើនគឺ ប្រតិកម្មរបស់វាជាមួយខ្លាញ់គោ ជាពិសេសក្នុងឡដុត (ដូចជា Oven Cleaner) ឬចាក់ចូលក្នុងបំពង់ទឹកស្ទះឱ្យបង្ហូរទឹក។ ក្នុងផលិតផលខ្លះសម្រាប់បង្ហូរបំពង់ទឹកស្ទះ គេប្រើលោហៈអាលុយមីញ៉ូមលាយជាមួយសូដ្យូមអ៊ីដ្រុកស៊ីត។ នៅពេលចាក់ទឹកប្រតិកម្មគីមីនឹងកើតឡើងដោយបង្កើតអ៊ីយ៉ុងអាលុយមីណាត និងឧស្ម័នអ៊ីដ្រូសែន។ ពពុះនៃឧស្ម័នអ៊ីដ្រូសែនធ្វើឱ្យទឹកមានសភាពខ្លាំងក្លា ដែលបង្កើនទំនាក់ទំនងនៃខ្លាញ់គោជាមួយសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ធ្វើឱ្យរលាយ របស់របរស្ទះកាន់តែលឿន៖

$$2Al(s) + 2OH^-(aq) + 6H_2O(l) \rightarrow 2[Al(OH)_4]^-(aq) + 3H_2(g)$$

សូដ្យូមអ៊ីដ្រុកស៊ីតក៏ប្រើក្នុងឧស្សាហកម្មអាហារផងដែរ ជាពិសេសផ្តល់អ៊ីយ៉ុងអ៊ីដ្រុកស៊ីតសម្រាប់ផ្តាច់ប្រូតេអ៊ីន។ ឧទាហរណ៍៖ គេបាញ់សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតលើដំឡូងបារាំង ដើម្បីឱ្យវាទន់ ហើយរបកសំបកវាចេញ។ ផ្លែអូលីវ (ស្រដៀងផ្លែម្កាញ) ត្រូវបានគេដាក់ត្រាំក្នុងសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ដើម្បីឱ្យសាច់វាទន់អាចបរិភោគបាន។ គេប្រើវា មិនប្រក្រតីមួយក្នុងផលិតផលនំប៉័ង pretzel (នំប៉័ងរូបរាងសញ្ញាអនន្ត)។ មុនដុតគេបានពាសសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតលើដុំម្សៅហើយគេដាក់អំបិលចូល។ សូដ្យូមអ៊ីដ្រុកស៊ីតហាក់ដូចជា ស៊ីម៉ង់ឱ្យក្រាមអំបិលជាប់ផ្ទៃក្រៅ។ នៅពេលដុតនំប៉័ង pretzel ឧស្ម័នកាបូនិចភាយឡើងបានទៅបំប្លែងសូដ្យូមអ៊ីដ្រុកស៊ីតទៅជាសូដ្យូមកាបូណាតម៉ូណូអ៊ីដ្រាតដែលមិនពុះ៖

$$2NaOH(s) + CO_2(g) \rightarrow Na_2CO_3.H_2O(s)$$

## អំបិលជំនួស

យើងត្រូវការសូដ្យូមក្លរួ 3g ក្នុងមួយថ្ងៃ ប៉ុន្តែនៅបស្ចិមប្រទេស អាហាររបស់ពួកគេមានអំបិលពី 8 ទៅ 10g។ ប្រសិនបើពួកគេបរិភោគទឹកបានគ្រប់គ្រាន់ បរិមាណប្រើប្រាស់នេះគ្មានបញ្ហាទេ។ ប៉ុន្តែសម្រាប់អ្នកដែលមានសម្ពាធឈាមខ្ពស់ ការកាត់បន្ថយការបរិភោគអ៊ីយ៉ុងសូដ្យូមបានបង្ហាញឱ្យឃើញថានឹងធ្វើឱ្យមានការកាត់បន្ថយសម្ពាធឈាម។ ដើម្បីឱ្យមានអ៊ីយ៉ុងសូដ្យូមតិចក្នុងខ្លួន គេមានអំបិលជំនួសជាច្រើន ដែលដាក់លក់នៅទីផ្សារដែលមានរសជាតិប្រៃតែមិនមានអ៊ីយ៉ុងសូដ្យូមទេ។ អំបិលទាំងនោះភាគច្រើនមានប៉ូតាស្យូមក្លរួ និងសមាសធាតុដទៃទៀតដែលមិនឱ្យមានរសជាតិល្វីង ដែលរសជាតិរបស់អ៊ីយ៉ុងប៉ូតាស្យូម។

អ្នកផលិតអំបិលសុទ្ធឆ្លាតមួយបានបញ្ជាក់ថា ផលិតផលរបស់គាត់មានសូដ្យូមតិចជាង 33% ព្រោះគាត់ចង់លក់ច្រើនទៅអ្នកភ័យខ្លាចជម្ងឺលើសឈាម។ ការបញ្ជាក់នេះពិតជាត្រឹមត្រូវតាមបច្ចេក

ទេស ដោយគេបានផលិតវាជាក្រាមអំបិលមានប្រហោង។ អំបិលទាំងនេះមានដង់ស៊ីតេតូចជាងអំបិលដែលមានក្រាមរាងជាគូប33%។ ដូចនេះ មួយស្លាបព្រានឹងមានអ៊ីយ៉ុងសូដ្យូម និងក្លរតិចជាង 33%។ នៅពេលអ្នកលាយបរិមាណអំបិលដដែលដូចធម្មតាលើម្ហូបរបស់អ្នក វានឹងកាត់បន្ថយអ៊ីយ៉ុងសូដ្យូម ប៉ុន្តែបើសិនជាអ្នកចង់បានភាពប្រៃដូចធម្មតា អ្នកនឹងត្រូវការអំបិលជំនួសនោះ 50% ច្រើនជាងអំបិលធម្មតា។

---

## ១១.៩ សូដ្យូមក្លរ

ទឹកសមុទ្រមាន**សូដ្យូមក្លរ** 3% និងសមាសធាតុខនិជច្រើនផ្សេងទៀត។ គេគណនាឃើញថាទឹកសមុទ្រមានអំបិល 19លានម៉ែត្រគូប ដែលធំជាងមាឌទ្វីបអាមេរិក។

អំបិលត្រូវបានគេផលិតដោយប្រើថាមពលព្រះអាទិត្យដើម្បីរំហួតទឹកសមុទ្រ ដែលជាប្រភពរកចំណូលរបស់ប្រទេសក្រកំពុងអភិវឌ្ឍន៏ដូចជាប្រទេសទួកគី កោះ Caicos និងប្រទេសកម្ពុជាជាដើម។ ប៉ុន្តែក្រោយមកគេក៏ឈប់ប្រើវិធីនេះ ដោយសារតែវាធ្វើឱ្យខាតបង់ប្រាក់ចំណូល និងការងារ។

សូម្បីតែមកដល់បច្ចុប្បន្ននេះ អំបិលនៅតែជាផលិតផលសំខាន់។ សូដ្យូមក្លរត្រូវបានគេប្រើជាធាតុគីមីសម្រាប់ផលិតអំបិលដែលល្អជាងសមាសធាតុរ៉ែដទៃទៀត ហើយពិភពលោកត្រូវការប្រហែល 150 លានតោនក្នុងមួយឆ្នាំ។ សព្វថ្ងៃគេជីកសូដ្យូមក្លរពីស្រទាប់រ៉ែក្រោមដី ដែលមានកម្រាស់រាប់រយម៉ែត្រ។ ស្រទាប់ទាំងនេះកើតឡើងនៅពេលបឹងធំៗបានហួតរហូតដល់ស្ងួតដែលមានអាយុកាលរាប់លានឆ្នាំមកហើយ។ ផ្ទាំងអំបិលប្រហែល 40% គេជីកដូចរ៉ែធ្យូងថ្មពីស្រទាប់ក្រោមដី ហើយបរិមាណនៅសល់គេដកចេញដោយបូមទឹកដាក់ចូលក្រោមដី ហើយបូមសូលុយស្យុងទឹកប្រៃដែលឆ្អែតចេញវិញ។

## ១១.១០ ប៉ូតាស្យូមក្លរ

**ប៉ូតាស្យូមក្លរ**ក៏ដូចជាសូដ្យូមក្លរដែរ មាននៅក្នុងបាតបឹងរីងសល់ពីសម័យបុរាណដែលសព្វថ្ងៃកប់ក្នុងជំរៅដ៏ជ្រៅ។ ប្រហែលជាពាក់កណ្តាលនៃប៉ូតាស្យូមក្លរលើពិភពលោក គឺនៅក្រោមដីក្នុងខេត្តមួយចំនួនក្នុងប្រទេសកាណាដា ដូចជា: Saskatchewan, Manitoba, និង New Brunswick។ នៅពេលដែលទឹកបឹងកាលពីសម័យបុរាណរីងស្ងួតនោះអំបិលរលាយទាំងអស់បានកកជាក្រាម។ ដូចនេះកំណក់ទាំងនោះមិនមែនជាប៉ូតាស្យូមក្លរទាំងអស់នោះទេ ប៉ុន្តែវាមានអំបិលផ្សេងទៀតដូចជា សូដ្យូមក្លរ ប៉ូតាស្យូមម៉ាញេស្យូមអិចសាអ៊ីដ្រាត($KMgCl_3.6H_2O$) ម៉ាញេស្យូមស៊ុលផាតម៉ូណូអ៊ីដ្រាត ($HgSO_4.H_2O$) និងអំបិលផ្សេងៗទៀត។

គេបានប្រើវិធីខុសប្លែកគ្នាជាច្រើនដើម្បីញែកសមាសធាតុអំបិលទាំងនេះ។ វិធីទីមួយគេគិតពីកំរិតរលាយខុសគ្នា ពោលគឺគេរំលាយល្បាយអំបិលក្នុងទឹកហើយប្រើវិធីរំហួត ប៉ុន្តែវិធីនេះគេត្រូវចំណាយអស់ថាមពលច្រើនក្នុងការរំហួតទឹកចេញ។ វិធីម្យ៉ាងទៀត គឺការបន្ថែមល្បាយជាក្រាមជាក់ចូលក្នុងសូលុយស្យុងសូដ្យូមក្លរួឆ្អែត។ នៅពេលដែលខ្យល់បក់ឆ្លងកាត់ល្បាយនេះ ក្រាមប៉ូតាស្យូមក្លរួស្អិតជាប់ទៅតាមពពុះ បន្ទាប់មកពពុះប៉ូតាស្យូមក្លរួ ក៏ត្រូវបានគេដួសចេញពីផ្ទៃលើទឹក។ រីឯសូដ្យូមក្លរួលិចចុះទៅបាតខាងក្រោម ហើយគេក៏បារវាចេញ។

វិធីទីបី ហាក់ដូចជាប្លែកបន្តិច ព្រោះវាជាដំណើរការអេឡិចត្រូស្តាទិច។ អង្គធាតុរឹងត្រូវបានកិនឱ្យក្លាយជាម្សៅម៉ត់ ហើយគេភ្ជាប់ចរន្តអគ្គិសនីទៅនឹងម្សៅនោះដោយដំណើរការកកិត។ ប៉ូតាស្យូមក្លរួទទួលបានបន្ទុកមួយដែលផ្ទុយពីសមាសធាតុរ៉ែដទៃទៀត។ បន្ទាប់មកគេចាក់ម្សៅអំបិលនោះទៅវត្ថុដែលមានបន្ទុកខ្លាំងពីរ។ ប៉ូតាស្យូមក្លរួស្អិតជាប់ទៅនឹងវត្ថុមួយដែលគេអាចយកវាចេញជាបន្តបន្ទាប់បានឯអំបិលផ្សេងទៀតជាប់នឹងវត្ថុមួយទៀតដែលមានបន្ទុកផ្ទុយពីប៉ូតាស្យូមក្លរួ។ ប៉ុន្តែ អំបិលផ្សេងជាសំណល់ ដែលត្រូវបានគេប្រើតិចតួច ហើយវាមានផលវិបាកនៃការបោះចោល។

ប៉ូតាស្យូមក្លរួ គេប្រើវាតែក្នុងការផលិតជាជី។ អ៊ីយ៉ុងប៉ូតាស្យូមជាធាតុដ៏សំខាន់មួយក្នុងការលូតលាស់របស់រុក្ខជាតិ ហើយរាល់ឆ្នាំគេប្រើប៉ូតាស្យូមក្លរួប្រហែល $4.5.10^7$ តោនលើពិភពលោកដែលជាហេតុធ្វើឱ្យវាក្លាយជាផលិផលគីមីដ៏សំខាន់មួយ។

## ១១.១១ សូដ្យូមកាបូណាត

មានតែលោហៈអាល់កាឡាំង (និងអ៊ីយ៉ុងអាម៉ូញ៉ូម) ប៉ុណ្ណោះ អាចបង្កើតកាបូណាតដែលរលាយក្នុងទឹក។ **សូដ្យូមកាបូណាត**ជាកាបូណាតនៃលោហៈអាល់កាឡាំងដែលសំខាន់ជាងគេ ហើយស្ថិតក្នុងទំរង់ជាម៉ូណូអ៊ីដ្រាត($Na_2CO_3.H_2O$) និងដេកាអ៊ីដ្រាត ($Na_2CO_3.10H_2O$) ដែលជាសូដាសម្រាប់លាងជំរះ។ បើសិនជាគេទុកក្រាមថ្លានៃដេកាអ៊ីដ្រាតក្នុងខ្យល់ស្ងួតវាបាត់បង់ម៉ូលេគុលទឹកនៃអ៊ីដ្រាតកម្ម (efflorescence) បង្កើតបានជាម្សៅសម៉ូណូអ៊ីដ្រាតៈ

$$Na_2CO_3.10H_2O(s) \rightarrow Na_2CO_3.H_2O(s) + 9H_2O(l)$$

### ក. ឧស្សាហកម្មសំយោគសូដ្យូមកាបូណាត

ប្រសិនគិតជាបរិមាណ សូដ្យូមកាបូណាតជាសមាសធាតុអសរីរាង្គដែលគេនិយមប្រើទី 9 នៅអាមេរិកខាងជើង។ គេទទួលបានវាពីសារធាតុខនិច trona ដែលមានល្បាយកាបូណាត-អ៊ីដ្រូសែនកាបូណាត ($Na_2CO_3.NaHCO_3.2H_2O$) គេនិយមហៅថាសូដ្យូមសេសគ្វីកាបូណាត (Sesqui)។ សេសគ្វី មានន័យថា "មួយកន្លះ" ហើយវាជាចំនួនអ៊ីយ៉ុងសូដ្យូមនៃកាបូណាតក្នុងសារធាតុខនិជនោះ។ សូដ្យូមសេសគ្វីកាបូណាតមិនមែនជាល្បាយនៃសមាសធាតុពីរទេ ប៉ុន្តែជាសមាសធាតុតែមួយដែលមាន

អ៊ីយ៉ុងកាបូណាត និងអ៊ីយ៉ុងអ៊ីដ្រូសែនកាបូណាតឆ្លាស់គ្នា ជាមួយនឹងអ៊ីយ៉ុងសូដ្យូម និងម៉ូលេគុលទឹកតាមសមាសមាត្រ 1:1:3:2 គឺ $Na_3(HCO_3).(CO_3).2H_2O$ ។ បរិមាណសារធាតុខនិជ tronaដ៏ច្រើនបំផុតលើពិភពលោកដែលគេរកឃើញនៅ Wyoming $4.5x10^{10}$ តោន ។

ក្នុងដំណើរការទង្វើម៉ូណូអ៊ីដ្រាត trona ជាសារធាតុរ៉ែគេជីកដូចជាធ្យូងថ្ម ដែលនៅក្រោមដីប្រហែល 400m ត្រូវបានគេកិនកំទេចរួច ហើយដុតក្នុងឡដែលបង្វិលបាន។ ទង្វើនោះបានបំប្លែងសេសគ្វីកាបូណាតទៅជា កាបូណាតៈ

$$2Na_3(HCO_3)(CO_3).2H_2O(s) \xrightarrow{\Delta} 3Na_2CO_3(s) + 3H_2O(g) + CO_2(g)$$

ជាលទ្ធផល សូដ្យូមកាបូណាតត្រូវគេរំលាយក្នុងទឹក ហើយគេច្រោះយកធាតុមិនសុទ្ធ ដែលមិនរលាយចេញ។ បន្ទាប់មកគេយកសូលុយស្យុងសូដ្យូមកាបូណាតទៅរំហួតរហូតដល់ស្ងួតដែលគេទទួលបានកាបូណាតម៉ូណូអ៊ីដ្រាត។ ដោយដុតផលិតផលនេះបន្តទៀត គេទទួលបានសូដ្យូមកាបូណាត :

$$Na_2CO_3.H_2O(s) \xrightarrow{\Delta} Na_2CO_3(s) + H_2O(g)$$

នៅប្រទេសផ្សេងទៀតគេផលិតសូដ្យូមអ៊ីដ្រូសែនកាបូណាតដោយដំណើរការ Solvay រឺ សូដាអាម៉ូញ៉ាក់។ ដំណើរការនេះមានប្រតិកម្មរវាងសូដ្យូមក្លរួ និងកាល់ស្យូមកាបូណាត :

$$2NaCl(aq) + CaCO_3(s) \leftrightarrow Na_2CO_3(aq) + CaCl_2(aq)$$

ប៉ុន្តែលំនឹងនៃប្រតិកម្មនេះមានទំនោរទៅខាងឆ្វេងច្រើន។ ដោយប្រើទឹកអាម៉ូញ៉ាក់លើប្រតិកម្មខាងលើប្រតិកម្មអាចត្រូវបានគេសំរេចបាន។ បញ្ហាដែលកើតឡើងជាមួយដំណើរការនោះគឺបរិមាណនៃកាល់ស្យូមក្លរួ ដែលផលិតបាន ព្រោះក្នុងទីផ្សារគេចង់ប្រើបរិមាណតិចជាងការផលិតក្នុងដំណើរការនេះ។ លើសពីនេះ ដំណើរការនេះត្រូវការថាមពលច្រើន ដែលធ្វើឱ្យវាត្រូវចំនាយច្រើនជាងវិធីtrona ។

## ខ. បំរើបំរាស់សូដ្យូមកាបូណាត

នៅ U.S ការផលិតផលសូដ្យូមកាបូណាតប្រហែល 50% ត្រូវបានគេប្រើនៅក្នុងការផលិតកែវ។ ក្នុងដំណើរការនេះ សូដ្យូមកាបូណាតចូលរួមប្រតិកម្មជាមួយស៊ីលីស្យូមឌីអុកស៊ីត (ខ្សាច់) ហើយនិងសមាសធាតុផ្សេងទៀតនៅសីតុណ្ហភាព1500ºC ។ រូបមន្តជាក់លាក់នៃផលិតផលអាស្រ័យលើផលធៀបនៃប្រតិករ។ ប្រតិកម្មនេះបង្កើតបានសូដ្យូមស៊ីលីកាត និង កាបូនឌីអុកស៊ីត :

$$Na_2CO_3(l) + xSiO_2(s) \xrightarrow{\Delta} Na_2O.xSiO_2(l) + CO_2(g)$$

សូដ្យូមកាបូណាតក៏ត្រូវបានប្រើក្នុងទឹកដើម្បីប្រើប្រាស់ដើម្បីជំរះអ៊ីយ៉ុងលោហៈអាល់កាលីណូទែរ៉ពីក្នុងដីដោយបំប្លែងវាឱ្យទៅជាកាបូណាតមិនរលាយ ដែលគេហៅថា "ទឹកទន់"។ អ៊ីយ៉ុងដែលគេត្រូវយកចេញ គឺអ៊ីយ៉ុងកាលស្យូមដែលវាមានកំហាប់ខ្ពស់នៅក្នុងទឹកប្រើប្រាស់ដែលមានប្រភពពីថ្មកំបោរ និងដីស :

$$CO_3^{2-}(aq) + Ca^{2+}(aq) \rightarrow CaCO_3(s)$$

## ១១.១២ សូដ្យូមអ៊ីដ្រូសែនកាបូណាត

គ្រប់លោហៈអាល់កាឡាំងទាំងអស់ (លើកលែងលីចូម) អាចបង្កើតជាអង្គធាតុរឹងជាមួយអ៊ីដ្រូសែនកាបូណាត ដែលគេតែងតែហៅថាជាប៊ីកាបូណាត។ យើងត្រូវយល់ថាកាចុងដែលមានដង់ស៊ីតេបន្ទុកទាបអាចធ្វើឱ្យស្ថេរភាពក្នុងអាញ៉ុងដែលមានដង់ស៊ីតេបន្ទុកខ្ពស់ អាចពន្យល់វត្តមាននៃអ៊ីដ្រូសែនកាបូណាតទាំងនេះ។

**សូដ្យូមអ៊ីដ្រូសែនកាបូណាត**រលាយក្នុងទឹកតិចជាងសូដ្យូមកាបូណាត។ ដូចនេះ គេអាចរៀបចំវាដោយឱ្យពពុះ $CO_2$ ឆ្លងកាត់សូលុយស្យុងកាបូណាតឆ្អែត :

$$Na_2CO_3(aq) + CO_2(g) + H_2O(l) \rightarrow 2NaHCO_3(s)$$

ការកម្តៅសូដ្យូមអ៊ីដ្រូសែនកាបូណាតវាបានបំបែកត្រឡប់ទៅសូដ្យូមកាបូណាតវិញ :

$$2NaHCO_3(s) \xrightarrow{\Delta} Na_2CO_3(s) + CO_2(g) + H_2O(g)$$

ប្រតិកម្មនេះផ្តល់នូវលក្ខណៈពិសេសមួយនៃសូដ្យូមអ៊ីដ្រូសែនកាបូណាត ដែលជាសមាសធាតុសំខាន់ក្នុងប្រដាប់ពន្លត់អគ្គិភ័យដោយប្រើម្សៅស្ងួត។ ម្សៅសូដ្យូមអ៊ីដ្រូសែនកាបូណាតអាចពន្លត់ភ្លើងបានបន្ថែមទៀត អង្គធាតុរឹងបំបែកជា $CO_2$ និងចំហាយទឹកដែលជាឧស្ម័នសម្រាប់ពន្លត់ភ្លើង។

ការប្រើប្រាស់សូដ្យូមអ៊ីដ្រូសែនកាបូណាតភាគច្រើនក្នុងឧស្សាហកម្មអាហារ ដែលធ្វើឱ្យនំឡើងមេ។ គេក៏ប្រើវាជាល្បាយ(មេនំ)នៃសូដ្យូមអ៊ីដ្រូសែនកាបូណាត និងកាល់ស្យូមឌីអ៊ីដ្រូសែនផូស្វាតជាមួយអាមីដុងដែលជាធាតុបន្ថែមបំពេញមាឌ។ កាល់ស្យូមឌីអ៊ីដ្រូសែនផូស្វាតជាអាស៊ីត នៅពេលមានសំណើម វាមានប្រតិកម្មជាមួយសូដ្យូមអ៊ីដ្រូសែនកាបូណាតឱ្យជា $CO_2$:

$$2NaHCO_3(s) + Ca(H_2PO_4)_2(s) \rightarrow Na_2HPO_4(s) + CaHPO_4(s) + 2CO_2(g) + 2H_2O(g)$$

## ១១.១៣ ប្រតិកម្មជាមួយអាម៉ូញ៉ាក់

លោហៈអាល់កាឡាំងមានលក្ខណៈពិសេសមួយ គឺវារលាយក្នុងអាម៉ូញ៉ាក់រាវឱ្យជាសូលុយស្យុងដែលមានពណ៌ខៀវ។ សូលុយស្យុងទាំងនោះចម្លងចរន្តអគ្គិសនី ហើយការចម្លងចរន្តសំខាន់ក្នុងសូលុយស្យុងគឺដោយសារអេឡិចត្រុងសុលវ៉ាតដោយអាម៉ូញ៉ាក់ $e^-$ (am) ដែលជាផលិតផលនៃអ៊ីយ៉ុងកម្មអាតូមសូដ្យូម:

$$Na(s) \rightleftharpoons Na^+(am) + e^-(am)$$

នៅពេលវារំហួត សូលុយស្យុងប្រែជាពណ៌ដូចសំរិទ្ធ ហើយមានលក្ខណៈដូចជាលោហៈរលាយ។ នៅពេលទុកយូរ ឬមានវត្តមានកាតាលីករនៃលោហៈឆ្លង សូលុយស្យុងបំបែកជាអំបិលអាមីត ($NaNH_2$) និងឧស្ម័នអ៊ីដ្រូសែន:

$$2Na^+(am) + 2NH_3(l) + 2e^- \rightarrow 2NaNH_2(am) + H_2(g)$$

## ១១.១៤ និដ្ឋភាពជីវៈ

យើងហាក់ដូចជាភ្លេចថាអ៊ីយ៉ុងសូដ្យូមនិងប៉ូតាស្យូមសំខាន់ណាស់សម្រាប់ជីវិត។ ឧទាហរណ៍ៈ យើងត្រូវការអ៊ីយ៉ុងសូដ្យូមយ៉ាងតិច 1g ក្នុងមួយថ្ងៃក្នុងអាហារ ប៉ុន្តែដោយសារតែការប្រើប្រាស់ក្នុងអាហារ ទើបធ្វើឱ្យមនុស្សមួយចំនួនមានបរិមាណលើស៥ដង។ ការទទួលបរិមាណលើសនៃអ៊ីយ៉ុងប៉ូតាស្យូកម្រមិនមានបញ្ហាទេ។ ជាក់ស្តែងកង្វះប៉ូតាស្យូមជាបញ្ហាវិញទេ ដូចនេះដើម្បីឱ្យអាហារ យើងមានបរិមាណវាគ្រប់គ្រាន់យើងគួរតែបរិភោគចេក និង កាហ្វេ។

អ៊ីយ៉ុងលោហៈអាល់កាឡាំងធ្វើឱ្យមានតុល្យភាពជាមួយប្រូតេអ៊ីន ដែលមានបន្ទុកអវិជ្ជមាននៅក្នុងខ្លួន។ ពួកវាក៏ជួយរក្សាសម្ពាធអូស្មូសក្នុងកោសិកា គឺការពារការស្រុតមិនដំណើរការ។ ក្នុងគីមីអសរីរាង្គយើងគិតពីភាពស្រដៀងគ្នានៃសូដ្យូម និងប៉ូតាស្យូម តែជីវៈគេគិតតែភាពខុសគ្នាវិញដែលមានសារៈសំខាន់។ កោសិកាស្រូបអ៊ីយ៉ុងសូដ្យូមចេញពីស៊ីតូប្លាសហើយស្រូបអ៊ីយ៉ុងប៉ូតាស្យូមចូលវិញ(តារាង 11.10)។ វាជាភាពខុសគ្នានៃកំហាប់អ៊ីយ៉ុងលោហៈអាល់កាឡាំងខាងក្នុង និងខាងក្រៅកោសិកា ដែលបង្កើតប៉ូតង់ស្យែលអគ្គិសនីនៅភ្នាសកោសិកា។

ភាពខុសគ្នានៃប៉ូតង់ស្យែលនោះ គឺជាមូលដ្ឋានគ្រឹះនៃដំណើរការជាច្រើន ដូចជាជីពចរបេះដូង ការញែកអង្គធាតុរលាយពុលនៃឈាមក្នុងតំរង់នោម និងការត្រួតពិនិត្យនៃសន្ទស្សន៍ចំណាំងបែរក្នុងកែវភ្នែក។ ខួរក្បាលមនុស្សអាចបង្កើតថាមពលបានច្រើនជាង 10W ពី $Na^+/K^+$ មកពីការស្រូបអ៊ីយ៉ុងប៉ូតាស្យូមចូល ហើយអ៊ីយ៉ុងសូដ្យូមចេញ ពីកោសិកាខួរក្បាល ដោយអង់ស៊ីមអាដេណូស៊ីនទ្រីផូស្វាត។ នៅពេលយើងជួបគ្រោះថ្នាក់ឬភ័យខ្លាច យើងមាននិមិត្តហេតុដូចជាបែកញើស និងស្បែកត្រជាក់ គឺដោយសារការជ្រាបចេញអ៊ីយ៉ុងលោហៈអាល់កាឡាំងជាច្រើនតាមភ្នាសកោសិកា។

អង់ស៊ីមអាចជ្រើសអ៊ីយ៉ុងនីមួយៗដោយសារវាមានចន្លោះដែលត្រូវគ្នានឹងទំហំអ៊ីយ៉ុង។ ថាមពលដេអ៊ីដ្រាតកម្ម របស់អ៊ីយ៉ុងនិមួយៗមានភាពខុសគ្នាដ៏សំខាន់ដែរ។

តារាង 11.10 កំហាប់នៃអ៊ីយ៉ុង ($mmol.L^{-1}$)

| អ៊ីយ៉ុង | $[Na^+]$ | $[K^+]$ |
|---|---|---|
| កោសិកាឈាមក្រហម | 11 | 92 |
| ប្លាស្មា | 160 | 10 |

ដើម្បីឱ្យអ៊ីយ៉ុងត្រូវនឹងទីកន្លែងសម្ព័ន្ធ ពួកវាត្រូវបាត់បង់ម៉ូលេគុលទឹកជាប់ជុំវិញដោយអ៊ីដ្រាត-កម្ម។ ចំពោះអ៊ីយ៉ុងសូដ្យូមមានដង់ស៊ីតេបន្ទុកខ្ពស់ជាង វាត្រូវការថាមពល 80kJ.mol$^{-1}$ ច្រើនជាង ដើម្បីរំដោះម៉ូលេគុលទឹកដែលនៅជាមួយវា ហើយផ្តល់អ៊ីយ៉ុងប៉ូតាស្យូមបង្កើតសម្ព័ន្ធមួយស្រួលជាង។

អង់ទីប្យូទិចមួយចំនួនមានប្រសិទ្ធភាព ព្រោះវាមានសមត្ថភាពផ្ទេរអ៊ីយ៉ុងសំខាន់ៗឱ្យឆ្លងកាត់ភ្នាសកោសិកា។ ម៉ូលេគុលសរីរាង្គទាំងនេះមានប្រហោងនៅផ្នែកកណ្តាលដែលផ្តល់ទីតាំងឱ្យអ៊ីយ៉ុងចូលបាន។ ឧទាហរណ៍ វ៉ាល់លីណូមីស៊ីន មានលំហតូចៗត្រឹមត្រូវសម្រាប់អ៊ីយ៉ុងប៉ូតាស្យូម តែមិនអាចដាក់អ៊ីយ៉ុងសូដ្យូមដែលមានទំហំធំបានទេ។ ដូចនេះតួនាទីរបស់ថ្នាំនេះ គឺរើសយកនិងដឹកនាំអ៊ីយ៉ុងប៉ូតាស្យូមឱ្យឆ្លងកាត់ភ្នាសកោសិកា។

## ១១.១៥ គំនូសបំព្រួញប្រតិកម្មនៃធាតុ

លោហៈអាល់កាឡាំងមានលោហៈសំខាន់ៗបី គឺលីចូម សូដ្យូម និងប៉ូតាស្យូម ដែលតាងប្រតិកម្មក្នុងគំនូសបំព្រួញដូចខាងក្រោម៖



## បញ្ញត្តិសំខាន់

- លោហៈក្នុងក្រុមទី1 មានដង់ស៊ីតេ ចំណុចរលាយ និងចំណុចរំពុះទាប
- លោហៈអាល់កាឡាំងមានប្រតិកម្មភាពខ្ពស់
- កាចុងដែលធំរបស់លោហៈអាល់កាឡាំង( លើកលែងលីតូម) ធ្វើឱ្យមានស្ថេរភាពជាមួយអាញ៉ុងធំដែលមានបន្ទុកទាប
- អំបិលនៃលោហៈក្នុងក្រុមទី១អាចរលាយបាន លើកលែងលោហៈអាល់កាឡាំងធំដូចជា ប៉ូតាស្យូម រុយប៊ីដ្យូម និងសេស្យូម ជាមួយអាញ៉ុងធំ
- ប្រតិកម្មលោហៈទាំងនេះជាមួយអ៊ីដ្រូសែនបានជាផលិតផលខុសៗគ្នាគឺអាស្រ័យលើទំហំកាចុង។

## ពាក្យគន្លឹះ

| | | |
|---|---|---|
| **លីចូម** | lithium | 11-10 |
| **សូដ្យូម** | sodium | 11-13 |
| **ដំណើរការ Downs** | Downs process | 11-13 |
| **ប៉ូតាស្យូម** | potassium | 11-14 |
| **ពិលបន្ទះខ័ណ្ឌ** | diaphragm cell | 11-18 |
| **សូដ្យូមក្លរ** | sodium chloride | 11-21 |
| **ប៉ូតាស្យូមក្លរ** | potassium chloride | 11-21 |
| **សូដ្យូមកាបូណាត** | sodium carbonate | 11-22 |
| **សូដ្យូមអ៊ីដ្រូសែនកាបូណាត** | sodium hydrogen carbonate | 11-24 |

## លំហាត់

១. សរសេរសមីការតាងប្រតិកម្ម:

ក. សូដ្យូម និងទឹក

ខ. រុយប៊ីដ្យូម និងអុកស៊ីសែន

គ. ក្រាមប៉ូតាស្យូមអ៊ីដ្រុកស៊ីត និងកាបូនឌីអុកស៊ីត

ឃ.ដុតកម្តៅសូដ្យូមនីត្រាត

២. សរសេរសមីការតាងប្រតិកម្ម:

ក. លីចូម និងអាសូត

ខ. ក្រាមសេស្យូឌីអុកស៊ីត (-1) ជាមួយទឹក

គ. ដុតកម្ដៅសូដ្យូមអ៊ីដ្រូសែនកាបូណាត

ឃ. ដុតកម្ដៅសូដ្យូមអាម៉ូញ៉ូមនីត្រាត

៣. តើលោហៈអាល់កាឡាំងជាតំណាងលោហៈទូទៅដូចម្ដេច? តើវាខុសគ្នាដូចម្ដេច?

៤. តើលោហៈណាដែលមានប្រតិកម្មភាពតិចជាងគេនៃលោហៈអាល់កាឡាំង?

៥. ចូររៀបរាប់លក្ខណៈគីមីពិសេសបីយ៉ាងរបស់លោហៈអាល់កាឡាំង?

៦. គេតាងលោហៈអាល់កាឡាំងមួយដោយអក្សរ M ហើយបង្កើតទំរង់វាជាមួយស៊ុលផាតអ៊ីដ្រាត $M_2SO_4.10H_2O$ ។ តើលោហៈនេះជាសូដ្យូម ឬជាប៉ូតាស្យូម? ចូរពន្យល់ ។

៧. ចូរពន្យល់ថាហេតុអ្វីបានជាសូដ្យូមអ៊ីដ្រុកស៊ីតរលាយជាមួយសូដ្យូមក្លរ ។

៨. ក្នុងដំណើរការ Downs ដើម្បីរៀបចំលោហៈសូដ្យូមៈ

ក. ហេតុអ្វីគេត្រូវប្រើអគ្គិសនីវិភាគក្នុងសូលុយស្យុងទឹក?

ខ. ហេតុអ្វីគេត្រូវថែមកាល់ស្យូមក្លរ?

៩. ហេតុអ្វីគេត្រូវប្រើសីតុណ្ហភាពនៅ 850 °C ក្នុងការទង្វើលោហៈប៉ូតាស្យូម?

១០. ចូររៀបរាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃ ពិលបន្ទះខ័ណ្ឌក្នុងការផលិតសូដ្យូមអ៊ីដ្រុកស៊ីត ។

១១. ចូរឱ្យឈ្មោះតាមប្រព័ន្ធនៃៈ

ក. សូដារលាក ខ. សូដាលាងជំរះ គ. សូដាផេះ

១២. ចូរឱ្យឈ្មោះតាមប្រព័ន្ធនៃៈ

ក. ប៉ូតាសរលាក ខ. Trona គ. ទឹកក្បុង

១៣. ចូរពន្យល់ពាក្យ

ក. Efflorescence ( មើល ១១,១១) ខ. Intercalation ( មើល ១១,៤ ក,)

១៤. ចូរពន្យល់ពាក្យ

ក. លោហៈស៊ុបពៃ ( មើល ១១,១) ខ. Deliquescent ( មើល ១១,៨)

១៥. ចូរសរសេរសមីការតាងប្រតិកម្មតាមការសំយោគ Solvay នៃសូដ្យូមកាបូណាត ។ តើដំណើរការនេះមានបញ្ហាសំខាន់ពីរយ៉ាងអ្វីខ្លះ?

១៦. ចូរពន្យល់ថាហេតុអ្វីបានជាមានតែលោហៈអាល់កាឡាំងដែលអាចបង្កើតជាអង្គធាតុរឹងមានស្ថេរភាពជាអំបិលជាមួយអ៊ីដ្រូសែនកាបូណាតបាន ។

១៧. ចូរពន្យល់យ៉ាងខ្លីថាហេតុអ្វីបានជាគេតែងតែចាត់ទុកថាអ៊ីយ៉ុងអាម៉ូញ៉ូមដូចជាលោហៈអាល់កាឡាំង ។

១៨. ចូរគូសដ្យាក្រាមអរប៊ីតាល់ម៉ូលេគុលដើម្បីពណ៌នាពីសម្ព័ន្ធអ៊ីដ្រូសែននៅក្នុងម៉ូលេគុលលី

ចូមអ៊ីដ្រូ។

១៩. ចូររកហេតុផលពីរយ៉ាងដែលគេមិនយកសេស្យូមឌីអុកស៊ីត(1-) តែគេយកប៉ូតាស្យូមឌីអុកស៊ីត (1-)ទៅប្រើនៅក្នុងប្រព័ន្ធសំអាតខ្យល់ឡើងវិញក្នុងយានអវកាស។

២០. តើអ៊ីយ៉ុងសូដ្យូម និងប៉ូតាស្យូមនៅត្រង់ទីតាំងណាដែលអាចការពារកោសិកាឱ្យរស់នៅបាន?

២១. ចូរសរសេរសមីការតាងប្រតិកម្មទាំងអស់ដែលមានក្នុងគំនូសបំប្រួញ?

## លំហាត់បន្ថែម

២២. ជំពូកនេះមិនមានពិពណ៌នាអំពីប្រង់ស្យូមដែលជាធាតុវិទ្យុសកម្ម។ ដោយផ្អែកលើទំនោរក្នុងក្រុម ចូររកលក្ខណៈសំខាន់ៗ និងសមាសធាតុនៃធាតុនេះ។

២៣. តើគេត្រូវការចរន្តអប្បបរមាប៉ុន្មាននៅ 7.0 V ដើម្បីផលិតលោហៈសូដ្យូម 1 តោន ក្នុងមួយថ្ងៃតាមរយៈពិល Down? គេសន្មតថាវាមានប្រសិទ្ធភាព 100% ហើយគេដឹងថាអេឡិចត្រុង 1 mol ត្រូវការ $9.65 . 10^4$ $A.s^{-1}$ ផារ៉ាដេនៃអគ្គិសនី។

២៤. ប្លាទីនអិចសាភ្លុយអរួ ($PtF_6$) មានចំណូលអេឡិចត្រុងខ្ពស់ (772 $kJ.mol^{-1}$)។ នៅពេលវាមានប្រតិកម្មជាមួយលោហៈលីចូមគេទទួលបានលីចូមភ្លុយអរួ $Li^+F^-$ មិនមែន $Li^+PtF_6^-$ ចូរពន្យល់។

២៥. ចូរពន្យល់ថាហេតុអ្វីបានជានៅក្នុងសេរី LiF, NaF, KF, RbF និងCaF មានតម្លៃ $\Delta H_f^0$ អវិជ្ជមានកាន់តែតូច រីឯនៅក្នុងសេរី LiI, NaI, KI, RbI និងCsI មានតម្លៃអវិជ្ជមានកាន់តែធំ។

២៦. ម៉ាសអាតូមលីចូមក្នុងតារាងខួបគឺ 6.941 $g.mol^{-1}$ ប៉ុន្តែគេមិនប្រើសមាសធាតុលីចូមជាស្តង់ដាវិភាគដំបូងទេ ព្រោះម៉ាសអាតូមរបស់វាប្រហែល 6.97 $g.mol^{-1}$។ ចូរពន្យល់?

២៧. តើសូដ្យូមភ្លុយអរួ ឬសូដ្យូមតេត្រាភ្លុយអរ៉ាត ($Na[BF_4]$) ដែលរលាយនៅក្នុងទឹកខ្លាំងជាង? ហេតុអ្វី?

២៨. ចូរកំណត់ថាតើសេស្យូម II ភ្លុយអរួបំបែកដោយឯកឯងជាសេស្យូមភ្លុយអរួឬ?

$$CsF_2(s) \rightarrow CsF(s) + 1/2F_2(g)$$

គេឱ្យថាមពលបណ្តាញនៃ $CsF_2$ គឺ 2250$kJ.mol^{-1}$ និងថាមពលអ៊ីយ៉ុងកម្មលើកទីពីរនៃសេស្យូមគឺ 2.430 $MJ.mol^{-1}$។ ទិន្នន័យបន្ថែមអាចដកស្រង់ចេញពីសៀវភៅ SI ហើយការគណនានេះនឹងផ្តល់

នូវបំរែបំរួលអង់តាល់ពី ។ ប្រតិកម្មឯកឯងនេះយើងត្រូវរកបំរែបំរួលថាមពលសេរីចេញពីទិន្នន័យអង់ត្រូពី និងអង់តាល់ពី ។ តើបំរែបំរួលអង់ត្រូពីធ្វើឱ្យមានការបំបែកនេះដែរឬទេ? ពន្យល់?

២៩. កាំអ៊ីយ៉ុងអ៊ីដ្រូវាស់ក្នុងបណ្តាញក្រោមរបស់លីចូមអ៊ីដ្រូ មាន 130 pm ប៉ុន្តែ ក្នុងបណ្តាញក្រោមសេស្យូមអ៊ីដ្រូមានកាំ 154 pm ។ ចូរពន្យល់តម្លៃខុសគ្នាពីរ ។

៣០. អង្គធាតុរឹងនៃសេស្យូមក្លរួមានប្រតិកម្មជាមួយឧស្ម័នអ៊ីដ្រូសែនក្លរួឱ្យជាសមាសធាតុមួយ ដែលមានផ្ទុកអាញ៉ុងប៉ូលីអាតូម ចូរសរសេររូបមន្តអាញ៉ុងនោះ ។ ប៉ុន្តែលីចូមក្លរួមិនមានប្រតិកម្មជាមួយអ៊ីដ្រូសែនក្លរួទេ ចូរពន្យល់ ។

៣១. សូលុយស្យុងដែលមានកំហាប់អ៊ីយ៉ុង $Li^+$, $K^+$, $F^-$និង $I^-$ ត្រូវបានគេរំហួតរហូតដល់ស្ងួត ។ តើអំបិលណាមានកំណកជាក្រោម LiF និង KI ឬជា LiI និង KF? ត្រួតពិនិត្យចំលើយរបស់អ្នកដោយគណនាថាមពលបណ្តាញដែល ។ (ប្រើសមីការ Kapustinskii នៅជំពូកទី 6 ផ្នែក 6.1) ។

៣២. នៅសីតុណ្ហភាពនិងសម្ពាធខ្ពស់ ប្រតិកម្មជំនួសនៃសម្ព័ន្ធកាបូននិងក្លរដោយសម្ព័ន្ធកាបូននិងភ្លុយអរ ដោយប្រើអាល់កាឡាំងភ្លុយអរូ MF :

$$R_3C - Cl + MF \rightarrow R_3C - F + MCl$$

ហេតុអ្វីនៅក្នុងប្រតិកម្មនេះគេចូលចិត្តប្រើប៉ូតាស្យូមភ្លុយអរូជាងសូដ្យូមភ្លុយអរូ?

៣៣. ហេតុអ្វីបានជាការបំបែករបស់ប៉ូតាស្យូម-40 បង្កើតបានជាកាល់ស្យូម-40?

# ចម្លើយលំហាត់

11.1 (a) $2\,Na(s) + 2\,H_2O(l) \rightarrow 2\,NaOH(aq) + H_2(g)$

(b) $Rb(s) + O_2(g) \rightarrow RbO_2(s)$

(c) $2\,KOH(s) + CO_2(g) \rightarrow K_2CO_3(s) + H_2O(l)$

(d) $2\,NaNO_3(s) \rightarrow 2\,NaNO_2(s) + O_2(g)$

11.5 គេមានករណីបីក្នុងចំណោមករណីដូចតទៅនេះ :

- សមាសធាតុគីមីទាំងអស់គឺរលាយនៅក្នុងទឹក
- ពួកវាតែងតែបង្កើតអ៊ីយ៉ុងដែលមានចំនួនអុកស៊ីតកម្ម +1
- សមាសធាតុរបស់ពួកវាភាគច្រើនជាអ៊ីយ៉ូនិច
- ដង់ស៊ីតេបន្ទុកទាបនៃអ៊ីយ៉ុងលោហៈអាល់កាឡាំងធ្វើឱ្យស្ថេរភាពជាមួយអាញ៉ុងធំបន្ទុកទាបដូចជាអ៊ីដ្រូសែនកាបូណាត ។
- សមាសធាតុរបស់ពួកវាកំររងអ៊ីដ្រាតម្មណាស់ ។

11.9 ពីព្រោះតែលំនឹងនៃប្រតិកម្មសំយោគមានទំនោរទៅខាងឆ្វេង ។

$$Na(l) + KCl(l) \rightarrow K(l) + NaCl(l)$$

ដើម្បីធ្វើឱ្យប្រតិកម្មរំកិលទៅខាងស្តាំ ប៉ូតាស្យូមដែលពុះនៅសីតុណ្ហភាពទាបជាងសូដ្យូម ត្រូវតែយកចេញជាបន្តបន្ទាប់ជាឧស្ម័ន ។

11.13 ក. ការបាត់បង់ទឹកដោយអំបិលអ៊ីដ្រាតកម្មក្នុងបរិស្ថានសើមទាប ។

ខ. លក្ខណៈគីមីស្រដៀងគ្នានៃធាតុមួយ និងធាតុនៅក្រោមខាងស្តាំរបស់វាក្នុងតារាងខួបគីមី ។

11.17 អ៊ីយ៉ុងអាម៉ូញ៉ូមជាអ៊ីយ៉ុងម៉ូណូវិជ្ជមាន ដូចជាលោហៈអាល់កាឡាំងដែរ ( មិនដូចជាលោហៈផ្សេងទៀតដែលមានបន្ទុក 2+ ឬខ្ពស់ជាង) អំបិលរបស់វាគឺរលាយទាំងអស់ ដូចជាអំបិលលោហៈអាល់កាឡាំងដែរ ទំហំរបស់វាគឺប្រហែលពាក់កណ្តាលនៃអ៊ីយ៉ុងលោហៈអាល់កាឡាំង ហើយអំបិលធម្មតាទាំងអស់របស់វាគ្មានពណ៌ ដូចអំបិលលោហៈអាល់កាឡាំង ។

11.21 លីចូម:

$6\ Li(s) + N_2(g) \rightarrow 2\ Li_3N(s)$

$2\ Li(s) + Cl_2(g) \rightarrow 2\ LiCl(s)$

$Li(s) + C_4H_9Cl(solv) \rightarrow LiC_4H_9(solv) + LiCl(s)$

$4\ Li(s) + O_2(g) \rightarrow 2\ Li_2O(s)$

$2\ Li(s) + H_2O(l) \rightarrow 2\ LiOH(aq) + H_2(g)$

$Li_2O(s) + H_2O(l) \rightarrow 2\ LiOH(aq)$

$2\ LiOH(aq) + CO_2(g) \rightarrow Li_2CO_3(aq) + H_2O(l)$

$Li_2O(s) + CO_2(g) \rightarrow Li_2CO_3(s)$

សូដ្យូម:

$2\ Na(s) + Cl_2(g) \rightarrow 2\ NaCl(s)$

$2\ Na(s) + H_2O(l) \rightarrow 2\ NaOH(aq) + H_2(g)$

$2\ Na(s) + O_2(g) \rightarrow Na_2O_2(s)$

$Na_2O_2(g) + H_2O(l) \rightarrow 2\ NaOH(aq) + H_2O_2(aq)$

$2\ NaOH(aq) + CO_2(g) \rightarrow Na_2CO_3(aq) + H_2O(l)$

$Na_2CO_3(aq) + CO_2(g) + H_2O(l) \rightarrow 2\ NaHCO_3(aq)$

$2\ Na(s) + 2\ NH_3(l) \rightarrow 2\ NaNH_2(NH_3) + H_2(g)$

$Na_2O_2(s) + CO_2(g) \rightarrow Na_2CO_3(s) + O_2(g)$

ប៉ូតាស្យូម

$Na(l) + KCl(l) \rightarrow K(g) + NaCl(l)$

$2\ K(s) + Cl_2(g) \rightarrow 2\ KCl(s)$

$K(s) + O_2(g) \rightarrow KO_2(s)$

$2\ KO_2(s) + 2\ H_2O(l) \rightarrow 2\ KOH(aq) + H_2O_2(aq) + O_2(g)$

$2\ K(s) + 2\ H_2O(l) \rightarrow 2\ KOH(aq) + H_2(g)$

$2\ KOH(aq) + CO_2(g) \rightarrow K_2CO_3(aq) + H_2O(l)$

$K_2CO_3(aq) + CO_2(g) + H_2O(l) \rightarrow 2\ KHCO_3(aq)$

$2\ KO_2(s) + CO_2(g) \rightarrow K_2CO_3(s) + 2\ O_2(g)$

$3\ K^+(aq) + [Co(NO_2)_6]^{3-}(aq) \rightarrow K_3[Co(NO_2)_6](s)$

## ចម្លើយលំហាត់បន្ថែម

11.25 នៅក្នុងស៊េរី LiF ទៅ CsF មានការកើនឡើងដោយមិនតាមលំដាប់នៃទំហំអ៊ីយ៉ុង ដូចនេះថាមពលបណ្ដាញនឹងថយចុះច្រើនជាងការរំពឹងទុក ។ ជាលទ្ធផលអង់តាលពីកំណនឹងថយចុះដែរ ។ ចំពោះស៊េរី LiI ទៅ CsI មានការថយចុះមិនតាមលំដាប់ទំហំអ៊ីយ៉ុងដែរ ដូចនេះថាមពលបណ្ដាញនឹងថយចុះតិចជាងការរំពឹងទុក ។ ជាលទ្ធផល អង់តាល់ពីកំណនឹងកើនឡើង ។

11.29 មានចំលើយពីរយ៉ាង : មានការចងសម្ព័ន្ធកូវ៉ាឡង់ខ្លះក្នុងលីចូមអីដ្រួ ដូចនេះកាត់បន្ថយចម្ងាយរវាង Li-H ឬថាអ៊ីយ៉ុងលីចូមតូចដែលឱ្យបណ្ដាញមានអ៊ីយ៉ុងអ៊ីដ្រួដែលប៉ះជាមួយគ្នា ហើយអ៊ីយ៉ុងលីចូមញ័រក្នុងចន្លោះបណ្ដាញ នេះជាការពិតនៃលីចូមអ៊ីយ៉ូដួ ។

11.33 កាល់ស្យូម-40 ជាណៃ្វយ៉ូមានស្ថេរភាពខ្លាំងដោយលក្ខណៈពីរ គឺមានស្រទាប់នៃប្រូតុង និងណឺត្រុងដែលពេញ ។